

CARAM Cambodia

Coordination of Action Research on AIDS and Mobility

# ការសិក្សាស្រាវជ្រាវពីស្ថានភាពសុខភាពរបស់ ពលករចំណាកស្រុកកម្ពុជា

## ស្តីពី

## “ការធ្វើតេស្តដោយបង្ខំ”

ឆ្នាំ ២០០៧

# មាតិកា


- ♦ **អក្សរកាត់** ........................................ i
- ♦ **បុព្វកថា** ........................................ ii
- ♦ **សេចក្ដីថ្លែងអំណរគុណ** ........................................ iii
- ♦ **សេចក្ដីសង្ខេបរួម** ........................................ iiii

**១. សេចក្ដីផ្ដើម**

- ♦ ១.១ ប្រវត្តិនៃការស្រាវជ្រាវ ........................................ ១-៣
- ♦ ១.២ វិសាលភាព និង ដែនកំណត់នៃការស្រាវជ្រាវ ........................................ ៣-៤
- ♦ ១.៣ វិធីសាស្ត្រនៃការស្រាវជ្រាវ ........................................ ៤

**២. ស្ថានភាពប្រទេស** ........................................ ៥-៧

**៣. ការបង្ហាញពីលទ្ធផលនៃការវិភាគ**

- ♦ **៣.១ មុនពេលធ្វើដំណើរ** ........................................ ៨-៣០
  - នីតិវិធីនៃការធ្វើតេស្ត
    - ការយល់ព្រមជាមុន
    - ការផ្ដល់ប្រឹក្សាមុន និង ក្រោយកាធ្វើតេស្ត
    - ការរក្សាការសម្ងាត់
    - យ៉េនឌ័រ និងវប្បធម៌
    - ការបង្ហាញ និងផ្ដល់នូវលទ្ធផល
    - ការធ្វើតេស្តបញ្ជាក់បន្ថែមពីលទ្ធផល
    - ការគ្រប់គ្រងមណ្ឌលផ្ដល់ប្រឹក្សា
    - ផលប៉ះពាល់នៃលទ្ធផល
    - ការទទួលសេវាព្យាបាល ថែទាំ និង គាំទ្រដល់ពលករ
    - ចំនួនដងនៃការធ្វើតេស្ត
    - តម្លាភាព និងភាពច្បាស់លាស់នៃពតិមានការធ្វើតេស្ត
    - ឧបករណ៍នៃការធ្វើតេស្ត

▪ ទិដ្ឋភាព និងតំលៃនៃការធ្វើតេស្ត
• ការត្រួតពិនិត្យគោលនយោបាយ និង នីតិវិធីនៃការធ្វើតេស្ត

♦ **៣.២ នៅប្រទេសទទួល** ........................................................................ ៣០-៣២
• នីតិវិធីនៃការធ្វើតេស្ត
• ការត្រួតពិនិត្យគោលនយោបាយ និង នីតិវិធីនៃការធ្វើតេស្ត

♦ **៣.៣ សមាហរណកម្ម** ........................................................................ ៣២

**៤. សេចក្តីសន្និដ្ឋាន និង អនុសាសន៍** ........................................................................ ៣៣-៣៥

**៥. ឯកសារយោង** ........................................................................ ៣៦

# អក្សរកាត់

- CARAM : Coordination of Action Research on AIDS and Mobility
- EPS : Employment Permit System
- FGD : Focus Group Discussion
- IDI : In-Dept Interview
- MoH : Ministry of Health
- MoLVT : Ministry of Labor and Vocational Training
- MoU : Memorandum of Understanding
- NCHADS : National Center for HIV/AIDS, Dermatology and STD
- QA : Quality Assurance
- QC : Quality Control
- VCCT : Voluntary Confidential Counseling and HIV Testing Center

# បុព្វកថា

ស្ថានភាពសុខភាពរបស់ពលករចំណាកស្រុក និងការសិក្សាស្រាវជ្រាវលើការធ្វើតេស្តដោយបង្ខំ គឺជាសមិទ្ធិផលមួយរបស់អង្គការខារ៉ាមកម្ពុជា និងជាឧបករណ៍ដ៏សំខាន់មួយសំរាប់ធ្វើការទាក់ទាញមតិគាំទ្រដើម្បីកាត់បន្ថយភាពងាយរងគ្រោះពីជំងឺកាមរោគ និង មេរោគអេដស៍/ជំងឺអេដស៍នៅក្នុងចំណោមពលករចំណាកស្រុក។ អង្គកាខារ៉ាមកម្ពុជាដែលប្រែថា **សកម្មភាពនៃកិច្ចសម្របសម្រួលលើការស្រាវជ្រាវអំពីមេរោគអេដស៍/ជំងឺអេដស៍ និងចល័តភាព** ដែលជាបណ្តាញរបស់អង្គការក្រៅរដ្ឋាភិបាលនៅអាស៊ី ធ្វើការងារជាមួយពលករចំណាកស្រុកទាំងមាន និង មិនមានឯកសារ ទាក់ទងនឹងការទាក់ទាញមតិគាំទ្រ ជាពិសេសទៅលើផ្នែកសុខភាព សិទ្ធិការងារ និងសិទ្ធិពលករ។ លេខាធិការដ្ឋានរបស់បណ្តាញអង្គកាខារ៉ាមអាស៊ី មានទីតាំងនៅទីក្រុង កូលាឡាំពួរ ប្រទេសម៉ាឡេស៊ី ដែលត្រូវបានផ្តល់បច្ចេកទេសដោយ សកលវិទ្យាល័យហ្វ្រីស នៅអាំស្ទែរដាំ ប្រទេសហូឡង់។

អង្គការខារ៉ាមកម្ពុជា បានផ្តល់នូវចំនេះដឹងដល់ពួកគេ តាមរយៈបទអន្តរាគមន៍នានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ពលករដែលមានឯកសារ និងមិនមានឯកសារ។ លើសពីនេះ អង្គកាខារ៉ាមធ្វើការជាមួយស្រ្តីជនជាតិវៀតណាមដែលធ្វើការនៅតាមសេវាកំសាន្ត និង ពលករខ្មែរដែលត្រៀមខ្លួនទៅធ្វើការនៅក្រៅប្រទេសដូចជា ប្រទេសថៃ ម៉ាឡេស៊ី និង សាធារណៈរដ្ឋកូរ៉េ។

ក្រុមការងាររបស់អង្គការខារ៉ាមកម្ពុជាដែលបានផលិត និង ធ្វើការសិក្សាស្រាវជ្រាវលើរបាយការណ៍នេះរួមមាន លោកស្រី **ទេព មុន្នី** លោកស្រី **ឯក សាឡុន** និងបុគ្គលិកស្ម័គ្រចិត្តមួយចំនួនទៀតដូចជា កញ្ញា **អ៊ិត សុភក្រ្ត័** និងលោកស្រី **ប្រាក់ សុភក្រ្ត័នារី** ព្រមទាំងមានការលើកទឹកចិត្ត និងគាំទ្រដោយលោក **យ៉ា ណារិទ្ធ** នាយកប្រតិបត្តិអង្គការខារ៉ាមកម្ពុជា ដែលក្នុងនោះផងដែរ ការសិក្សាស្រាវជ្រាវនេះ ត្រូវដឹកនាំដោយ លោក **មាស សារ៉ៃណេត** ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៧

**យ៉ា ណារិទ្ធ**

នាយកប្រតិបត្តិ

# សេចក្តីថ្លែងអំណរគុណ

អង្គការខារ៉ាមកម្ពុជាសូមថ្លែងអំរណគុណយ៉ាងខ្លាំងផងដែរដល់ក្រុមការងារស្រាវជ្រាវថ្នាក់តំបន់ដែលមាន លោក សាស្រ្តាចារ្យ **អ៊ី វ៉ានវូលហ្វឿរ** លោកស្រី **កូរនីលីកើរ កេសើរ** លោកស្រី **ម៉ារ៉ា គ្វីសាដា** លោកស្រី **ដីល រូប៉ា ការីម** និង លោកស្រី **មី ឆែលរ៉ូហ្គឿរ** ដែលបានជួយសម្របសម្រួលការសិក្សាស្រាវជ្រាវនេះជាមួយដៃគូទាំងអស់ ក៏ដូចជាអង្គការខារ៉ាមផងដែរ។ ការសិក្សាស្រាវជ្រាវនេះត្រូវបានទទួលនូវការផ្តល់បច្ចេកទេស និងអនុសាសន៏ពីក្រុមការងារថ្នាក់តំបន់ដើម្បីជាបទពិសោធន៏ និងការរៀនសូត្រសំរាប់ការសិក្សាស្រាវជ្រាវនៅពេលអនាគត។

ក្នុងនោះដែរ ក៏សូមថ្លែងអំណរគុណជាពិសេសដល់ លោក **សាស្រ្តាចារ្យ អ៊ី វ៉ាន** ដែលបានចំណាយពេលវេលា ព្រមទំាងកំលំាងកាយចិត្តក្នុងការសម្របសម្រួលជាមួយដៃគូរទំាងអស់ សំរាប់ការសិក្សាស្រាវជ្រាវថ្នាក់តំបន់នេះ ដែលវាជាឧបករណ៏មួយមានសារៈសំខាន់សំរាប់ការទាក់ទាញមតិគំាទ្រ ថ្នាក់ប្រទេស និងថ្នាក់តំបន់។

ព្រមទំាង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទីភ្នាក់ងាររដ្ឋាភិបាលមានដូចជា **ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ដែលមានមជ្ឈមណ្ឌលជាតិសើរស្បែក និងកាមរោគ មន្ទីរពេទ្យព្រះកុសមះ ពេទ្យព្រះកេតុមាលា ពេទ្យសហពន្ធ័រុស្សី មណ្ឌលសុខភាពទួលគោក វិទ្យាស្ថានជាតិប៉ាស្ទ័រ និងស្ថាបន័អង្គការក្រៅរដ្ឋាភិបាលមានដូចជា គ្លីនិចអង្គការមិច និងគ្លីនិចអង្គការរ៉ាក់ ព្រមទំាង គ្លីនិចឯកជនចន្ទ្រា និងក្រុមហ៊ុនជ្រើសរើសពលករ ហ្វីលីម័រ ក្វាតា និង មណ្ឌលអេលីត សាខាក្រុមហ៊ុនស៊ី អិល អេស** ដែលបានចំណាយពេលវេលានិងផ្តល់នូវឯកសារមួយចំនួនដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះអាចបញ្ចប់ទៅតាមពេលវេលាមួយកំណត់។ ប្រសិនបើពុំមានចូលរួមចំណែកពីភាគីដែលពាក់ពន្ធ័ ក្នុងការផ្តល់ការសហការ និងគំាទ្រនោះទេ ការសិក្សានេះមិនអាចប្រព្រឹត្តទៅ និងចប់តាមពេលវេលានោះឡើយ។

# សេចក្តីសង្ខេបរួម

**អង្គការខារ៉ាមកម្ពុជា**ជាសមាជិករបស់បណ្តាញអង្គការខារ៉ាមអាស៊ី ដែលមានដៃគូជាងម្ភៃប្រទេស នៅ អាស៊ី និង អាស៊ីអាគ្នេយ៍។ ស្ថានភាពសុខភាពរបស់ពលករចំណាកស្រុកទាក់ទង នឹងការធ្វើតេស្តដោយបង្ខំជាសមិទ្ធិផលមួយរបស់ អង្គការខារ៉ាមកម្ពុជាដែលបានផលិត ក្នុងគោលបំណងដើម្បីធ្វើការទាក់ទាញមតិគាំទ្រ និង កាត់បន្ថយភាពងាយរងគ្រោះ របស់ពលករទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺកាមរោគ។ ការសិក្សាបានធ្វើ ឡើងជាលក្ខណៈថ្នាក់តំបន់ និង ប្រទេស ដែលក្នុងនោះដែរ បានផ្តោតលើដំណើរការនៃនីតិវិធីការធ្វើតេស្តចំពោះពលករដែលត្រូវទៅធ្វើការ នៅក្រៅប្រទេស ដូចជា ប្រទេសថៃ ម៉ាឡេស៊ី និងសាធារណៈរដ្ឋកូរ៉េ។

ស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងពលករត្រូវបានកំណត់ដោយក្រុមការងារស្រាវជ្រាវ ដើម្បីធ្វើការសំភាសន៍ និង ពិភាក្សារួមមាន **ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្លីនិចជាតិសើស្បែក និងកាមរោគ (ផ្សារដេប៉ូ) មន្ទីរពេទ្យព្រះកុសមៈ ពេទ្យព្រះកេតុមាលា ពេទ្យរុស្សី មណ្ឌលសុខភាពទួលគោក វិទ្យាស្ថាន ជាតិប៉ាស្ទ័រ គ្លីនិចអង្គការមិច អង្គការរ៉ាក់ គ្លីនិចឯកជនចន្ទ្រា និងក្រុមហ៊ុនជ្រើសរើសពលករ ហ្វីលីម័រ ក្វាតា និង មណ្ឌលបណ្តុះបណ្តាល អេលីត សាខាក្រុមហ៊ុនស៊ី អិល អេស**។ លើសពីនេះទៅទៀត ពលករដែលត្រៀម ទៅធ្វើការនៅក្រៅប្រទេស និងអ្នកត្រលប់ មកពីធ្វើការនៅក្រៅប្រទេសចំនួន **៨៦នាក់** ត្រូវបានសំភាសន៍ ដើម្បីស្វែងយល់ពីបញ្ហាដែលពួកគេបានជួបប្រទះនៅប្រទេស បញ្ជូន និងប្រទេសទទួល ទាក់ទងនឹងដំណើរការ ក៏ដូចជានីតិវិធីនៃការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ ដែលធ្វើដោយ អ្នកផ្តល់ប្រឹក្សា។ ក្នុងនោះដែរ ស្ត្រីជនជាតិ វៀតណាមដែលធ្វើការនៅតាមសេវាកំសាន្តនានានៅក្រុងភ្នំពេញ ចំនួន**១៤នាក់** ដែលមាន **២នាក់** ជាអ្នកផ្ទុក មេរោគអេដស៍/ជំងឺអេដស៍ និងមានបទពិសោធន៍ជាមួយនឹងការធ្វើតេស្ត។

តួយ៉ាង រាល់ការវិភាគ និងការសិក្សាស្រាវជ្រាវដែលរកឃើញគឺបានផ្តោតលើបញ្ហាមួយចំនួនដូចជា **នីតិវិធី នៃការធ្វើតេស្ត ការយល់ព្រមជាមុន ការផ្តល់ប្រឹក្សាមុន និងក្រោយការធ្វើតេស្ត ការរក្សាកាសម្ងាត់ យ៉េនឌ័រ និង វប្បធម៌ ការបង្ហាញ និងផ្តល់នូវលទ្ធផលតេស្ត ការធ្វើតេស្តបញ្ជាក់បន្ថែមពីលទ្ធផល ការគ្រប់គ្រងមណ្ឌលផ្តល់ប្រឹក្សា ផលប៉ះពាល់ នៃលទ្ធផល ការទទួលសេវាព្យាបាល ថែទាំ និងគាំទ្រ ចំនួនដងនៃការធ្វើតេស្ត តម្លាភាព និងភាពច្បាស់លាស់ នៃពតិមានការធ្វើតេស្ត ឧបករណ៍នៃការធ្វើតេស្ត និង ទិដ្ឋភាពនិងថ្លៃនៃមណ្ឌលធ្វើតេស្ត** ដែលបានកើតឡើងចំពោះពលករ នៅពេលដែលត្រូវបានគេធ្វើតេស្តនៅមណ្ឌលធ្វើតេស្ត ក៏ដូចជាមណ្ឌលសុខភាព គ្លីនិចឯកជន និង នៅប្រទេសទទួលជារៀង រាល់ឆ្នាំ។ ដោយឡែក រាល់អនុសាសន៍ ដែលបានផ្តល់យោបល់ នៅក្នុងរបាយការណ៍ វាឆ្លុះបញ្ចាំងពីការដែលបានរកឃើញ និង ទស្សនៈរបស់អ្នកសរសេររបាយការណ៍ប៉ុណ្ណោះ។

# ការសិក្សាស្រាវជ្រាវពីស្ថានភាពសុខភាពរបស់ពលករចំណាកស្រុកកម្ពុជា
# ស្តីពី
# ការធ្វើតេស្តដោយបង្ខំ ឆ្នាំ ២០០៧

## ១. សេចក្តីផ្តើម

- **១.១ ប្រវត្តិនៃការស្រាវជ្រាវ:**

ការសិក្សាស្រាវជ្រាវពីស្ថានភាពសុខភាពរបស់ពលករចំណាកស្រុកកម្ពុជា ទាក់ទងនិង ប្រធានបទ **ការធ្វើតេស្តដោយបង្ខំ**ត្រូវបានកំណត់ដោយបណ្តាញអង្គការខារ៉ាមអាស៊ីតាមរយៈសិក្ខាសាលាមួយបន្ទាប់ពីកិច្ចសិក្សាស្រាវស្រាវពីការទទួលសេវារបស់ពលករចំណាកស្រុកត្រូវបានគេផ្សព្វផ្សាយឡើង នៅជំហ៊ាន ទីមួយនៃការស្រាវជ្រាវ។ ក្នុងការសិក្សាស្រាវជ្រាវនេះដែរ ត្រូវបានគេរៀបចំឡើងជាលក្ខណៈថ្នាក់ប្រទេស និងថ្នាក់តំបន់ ដែលវាជាឧបករណ៏មួយដ៏សំខាន់ សំរាប់ធ្វើការទាក់ទាញមតិគាំទ្រ ដែលប្រធានបទនេះមិនសូវជា មានផ្តោតការយកចិត្តទុកដាក់នោះទេ ព្រោះថា មានសិក្សាស្រាវជ្រាវជាច្រើនដែលបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ទាក់ទងនឹងប្រធានបទមេរោគអេដស៏/ជំងឺអេដស៏ ការជួញដូរ និង ចំណាកស្រុក។

ការសិក្សា បានផ្តោតទៅលើការធ្វើយ៉ាងណាអោយពលករចំណាកស្រុកទទួលនូវសេវាធ្វើតេស្តឈាមរកមេរោគអេដស៏/ជំងឺអេដស៏ដោយសោមនស្ស ដែលវាជាកត្តាសំខាន់នៃការស្រាវជ្រាវ និងមានបញ្ជាក់ជូននូវចំនុចខាងក្រោមព្រោះថា ប្រទេសកម្ពុជាបានបញ្ជូនពលកររបស់ខ្លួនទៅធ្វើការនៅក្រៅប្រទេស ដោយយោងទៅលើអនុក្រឹត្រលេខ ៥៧ ដែលបានចុះហត្ថលេខានៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៧។ ចាប់តាំងពីពេលនោះមកមានក្រុមហ៊ុនជ្រើសរើសពលករចំនួនជាង ៣០ ដែលបានប្រតិបត្តិការអាជីវកម្មរបស់ខ្លួនក្នុងការបញ្ជូនពលករខ្មែរទៅធ្វើនៅក្រៅប្រទេសដូចជា ប្រទេសថៃ ម៉ាឡេស៊ី អារ៉ាប៊ីសាអូឌីត និងសាធារណរដ្ឋកូរ៉េ ដែលភាគច្រើនពួកគេត្រូវបានគេអោយធ្វើការជាអ្នកធ្វើការតាមផ្ទះ ចំការ ភោជនីយដ្ឋាន និង ក្នុងវិស័យឧស្សាហកម្មផ្សេងទៀត។

ម៉្យាងវិញទៀត មានករណីបោកបញ្ឆោត និងការជួញដូរមនុស្ស ត្រូវបានធ្វើឡើងដោយក្រុមហ៊ុន មួយចំនួនក្នុងការទាញយកផលប្រយោជន៏ តាមរយៈការជ្រើសរើសពលករខ្មែរដើម្បីបញ្ជូនទៅធ្វើការនៅក្រៅប្រទេស។ ហេតុដូច្នេះ ទើបក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការរឹតបន្តឹងដោយបានចេញនូវសេចក្តីជូនដំណឹង

មួយនៅក្នុងខែតុលា ឆ្នាំ២០០៦ បានទទួលស្គាល់ក្រុមហ៊ុនចំនួន១២ ដែលមានលក្ខណៈស្របច្បាប់ និងអាចប្រតិបត្តិការអាជីវកម្មរបស់ខ្លួនបាន។

បរិបទនៃការបញ្ជូនកំលាំងពលកម្មទៅធ្វើការនៅក្រៅប្រទេស ភាគច្រើនពលករត្រូវបានគេធ្វើពិនិត្យសុខភាព ជាពិសេស ការធ្វើតេស្តរកមេរោគអេដស៍/ជំងឺអេដស៍ រោគថ្លើម និង ការមានផ្ទៃពោះ មុនពេលធ្វើការបញ្ជូនពួកគេទៅធ្វើការនៅប្រទេសទទួល ដែលការពិនិត្យសុខភាពនេះធ្វើឡើងដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ម៉្យាងវិញទៀត បញ្ហានេះជាកាតព្វកិច្ច និងតំរូវការចាំបាច់ ដែលត្រូវធ្វើឡើង បើទោះជាមានលក្ខណៈផ្ទុយពីច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ភាគច្រើននៃការពិនិត្យសុខភាពទៅលើពលករចំណាកស្រុកត្រូវបានធ្វើឡើងដោយវេជ្ជបណ្ឌិត បុគ្គលិកពេទ្យដែលមិនមានជំនាញ ដោយគ្រាន់តែធ្វើការបូមឈាមរបស់ពលករយកទៅមន្ទីរពិសោធន៍ និងមិនមានការផ្តល់ប្រឹក្សាមុន និង ក្រោយការធ្វើតេស្តមុននឹងបញ្ជូនពួកគេទៅធ្វើការពិនិត្យសុខភាព និង ធ្វើតេស្តឈាមរកមេរោគអេដស៍/ជំងឺអេដស៍ ដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ វាជាបញ្ហាគ្រោះថ្នាក់សំរាប់ពលករដែលលទ្ធផលនៃការធ្វើតេស្តឈាមរកមេរោគអេដស៍/ជំងឺអេដស៍មានលក្ខណៈវិជ្ជមាន ដែលនាំអោយពួកគេអាចឈានទៅដល់ការធ្វើអត្តឃាត ឬ រស់នៅដោយមិនមានសេវាគាំពារ ហើយត្រូវបានរើសអើង ពីអ្នកជិតខាង មិត្តភក្រ្ត័ និង សង្គម ដែលប្រាសចាកពីគោលបំណងរបស់ពួកគេក្នុងការស្វែងរកការងារធ្វើនៅក្រៅប្រទេសដើម្បី រកថវិកាមកផ្គត់ផ្គង់គ្រួសារ តែបែរជាត្រូវបញ្ជូនទៅសហគមន៍របស់ពួកគេវិញ ដោយសារតែការបរាជ័យ នៃការពិនិត្យ សុខភាព។ ពលករចំណាកស្រុកកម្ពុជា ជានិច្ចកាលតែងតែទទួលរងនូវភាពងាយរងគ្រោះ នៃគោលការណ៍ពិនិត្យ សុខភាព ដែលធ្វើឡើងដោយប្រទេសកំណើត និង ប្រទេសទទួល ក៏ព្រោះតែពួកគេកង្វះនូវពតិមានពីនីតិ វិធីនៃការពិនិត្យសុខភាព ការប្រើប្រាស់នូវវាក្យសព្ទ័វេជ្ជសាស្រ្តដោយបុគ្គលិកសុខាភិបាល/គ្រូពេទ្យ ឧបសគ្គ ចំពោះភាសា ការរើសអើងដោយបុគ្គលិកសុខាភិបាល/គ្រូពេទ្យ ការរើសអើងពីវប្បធម៌ យ៉េនឌ័រ និងឥរិយាបទរបស់បុគ្គលិកសុខាភិបាល/គ្រូពេទ្យចំពោះពលករ។

ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវនេះបានរួមបញ្ចូលនូវនីតិវិធីនៃដំណើរការ ការធ្វើតេស្តចំពោះពលករចំណាកស្រុកដែលត្រៀមខ្លួនទៅធ្វើការនៅក្រៅប្រទេសដូចជា ថៃ ម៉ាឡេស៊ី និង សាធារណៈរដ្ឋកូរ៉េ តាមរយៈក្រុមហ៊ុនជ្រើសរើសពលករស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងម៉្យាងវិញទៀត ក៏បានរួមបញ្ចូលនូវស្ថាប័នដែលពាក់ពន្ធ័មួយចំនួនទៀតដូចជា គ្លីនិកឯកជន មន្ទីរពេទ្យនៅរាជធានីភ្នំពេញ និង បណ្តាខេត្តមួយចំនួនដែលជាដៃគូ របស់ក្រុមហ៊ុនជ្រើសរើសពលករ។

ក្នុងនោះដែរ ការសិក្សាស្រាវជ្រាវនេះទៀតសោត បានរួមចំណែកក្នុងការបំពេញនូវចំនុចខ្វះខាតមួយចំនួនទាក់ទងទៅនឹងដំណើរការនៃការពិនិត្យសុខភាព ក៏ដូចជាការធ្វើតេស្តឈាមរកមេរោគអេដស៍/ជំងឺអេដស៍ ចំពោះពលករដែលត្រៀមក៏ដូចជាអ្នកដែលមានបំណងទៅធ្វើការនៅក្រៅប្រទេស ដោយធ្វើយ៉ាងណា អោយប្រាកដថា ពតិមានពី ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ ជំងឺអេដស៍ និងគោលការណ៍ដទៃទៀតត្រូវបានគេផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ពលករ អ្នកពាក់ពន្ធ័ ភ្នាក់ងារឯកជន និង អ្នកផ្តល់ប្រឹក្សាពីការធ្វើតេស្តឈាមរកមេរោគអេសដ៏/ជំងឺអេដស៍ ដើម្បីឱ្យពួកគេអាចអនុវត្តទៅតាមតួនាទីរបស់ខ្លួន។

- **១.២ វិសាលភាព និង ដែនកំណត់នៃការសិក្សាស្រាវជ្រាវៈ**

ការសិក្សាស្រាវជ្រាវពីស្ថានភាពសុខភាពរបស់ពលករចំណាកស្រុកនេះទាក់ទង នឹងការធ្វើតេស្តឈាមដោយបង្ខំ ត្រូវបានគេធ្វើឡើងដើម្បីកំណត់នូវបញ្ហារបស់ពលករដែលត្រូវធ្វើតេស្តឈាមនៅកន្លែងធ្វើតេស្ត មុនពេលចាកចេញទៅធ្វើការនៅក្រៅប្រទេស និងខណៈដែលពួកគេស្នាក់នៅក្នុងប្រទេសទទួល ដែលតំរូវអោយមានការធ្វើតេស្តសុខភាពជារៀងរាល់ឆ្នាំផងដែរ។ បញ្ហាចំបងសំរាប់ការសិក្សានេះគឺ ផ្តោតលើវដ្តនៃនីតិវិធីការ តេស្តឈាមដែល ធ្វើឡើងដោយអ្នកផ្តល់ប្រឹក្សា។ ក្រៅពីនេះ ការសិក្សានេះមិនបានគ្រប់ដណ្តប់ទៅ លើប្រធានបទសុខភាពផ្លូវចិត្ត យ៉េនឌ័រ និង ការកេងប្រវ័ញ្ចកំលាំងពលកម្មនោះទេ។ ក្នុងនោះដែរ ការសិក្សានេះបានផ្តោតទៅលើទស្សនៈពីរ ដែលទីមួយគឺ **ទស្សនៈនៃប្រទេសបញ្ជូន** ដែលបានបញ្ជូនពលករខ្មែរទៅធ្វើការដោយ ស្របច្បាប់នៅប្រទេស ថៃ ម៉ាឡេស៊ី និង សាធារណៈរដ្ឋកូរ៉េ ដែលភាគច្រើនពួកគេទៅធ្វើការជាអ្នកជំនួយការនៅតាមផ្ទះ រោងចក្រ សហគ្រាស ភោជនីយដ្ឋាន និង ចំការ ដោយមិនរាប់បញ្ចូលអ្នកដែលទៅធ្វើការមិនស្របច្បាប់នៅប្រទេសថៃ ជាអ្នកនេសាទ អ្នកសុំទាន និង វិស័យផ្សេងទៀតនោះទេ។ ទីពីរ ទស្សនៈនៃ**ប្រទេសទទួល**ដែលស្ត្រីជនជាតិវៀតណាម ធ្វើការនៅតាមសេវាកំសាន្តនានា នៅក្នុងរាជធានីភ្នំពេញដូចជានៅតាមហាងម៉ាស្សា កាត់សក់ និង ក្លឹបរាត្រី ផ្សេងៗ ដើម្បីកំណត់នូវបញ្ហាដែលពួកគេជួបប្រទះតាមរយៈដំណើរការនៃការពិនិត្យសុខភាព ព្រោះថាពួកគេត្រូវ បានគេដឹងថាជាពលករចំណាកស្រុកមិនមានឯកសារ។

លើសពីនេះ ការសិក្សាមិនបានផ្តោតទៅដល់គ្រប់អ្នកផ្តល់ប្រឹក្សាដែលកំពុងធ្វើការនៅតាម មណ្ឌលធ្វើតេស្តឈាមរកមេរោគអេដស៍/ជំងឺអេដស៍ និង ភាគីដែលពាក់ពន្ធ័នឹងដំណើរនៃការធ្វើតេស្តទាំងអស់នោះទេ។ ការសិក្សានេះត្រូវបានគេកំនត់និងជ្រើសរើសយកតែភាគីស្ថាប័នប៉ុណ្ណោះ ដោយយោងទៅលើពេលវេលាមានកំណត់ ក្នុងនោះដែរតំណាងស្ថាប័នរដ្ឋាភិបាលចំនួន០៧ដែលពាក់ពន្ធ័នឹងការធ្វើតេស្តឈាមត្រូវបានសំភាសន៏ដែលរួមមាន នាយកដ្ឋានពេទ្យការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌលជាតិនៃជំងឺសើរស្បែក និង កាមរោគ (ផ្សារដេប៉ូ) មន្ទីរពេទ្យព្រះកុសមៈ មន្ទីរពេទ្យរុស្ស៊ី មន្ទីរពេទ្យព្រះកេតុមាលា មណ្ឌលសុខភាពទួលគោក និង

វិទ្យាស្ថានជាតិបាស្ទ័រ និងអង្គការក្រៅរដ្ឋាភិបាលចំនួន ២ រួមមាន អង្គការម៉ិច និង សមាគន៍ថែទាំសុខភាពគ្រួសារ — រ៉ាក់ និងគ្លីនិកឯកចន្ទ្រា និង ក្រុមហ៊ុនជ្រើសរើសពលករចំនួន៣ មានដូចជា ក្រុមហ៊ុនហ្វីលីម័រ ក្វាតា និង មណ្ឌលអេលីត សាខាក្រុមហ៊ុនស៊ី អិល អេស។ លើសពីនេះទៅទៀត ពលករចំណាកស្រុកខ្មែរចំនួន **៨៦នាក់** ដែលត្រៀមទៅធ្វើការនៅក្រៅប្រទេស និង អ្នកត្រលប់មកពីប្រទេសក្រៅ ត្រូវបានសំភាសន៍ ដើម្បីកំណត់ពីបញ្ហា ដែលជួបប្រទះរបស់ពួកគេនៅប្រទេសទទួល និង ប្រទេសដើមទាក់ទង នឹងការធ្វើតេស្តឈាមរកមេរោគអេដស៍/ ជំងឺអេដស៍ និង នីតិវិធីនៃការធ្វើតេស្តឈាមដែលធ្វើឡើងដោយអ្នកផ្តល់ប្រឹក្សា។ ម៉្យាងវិញទៀត ស្ត្រីជនជាតិ វៀតណាមចំនួន **១៤នាក់** ដែលធ្វើការនៅតាមសេវាកំសាន្ត ត្រូវបានគេសំភាសន៍ផងដែរ ដែលក្នុងនោះមាន អ្នកផ្ទុកមេរោគដ៏ចំនួន **២នាក់** ដែលមានបទពិសោធន៍ក្នុងការធ្វើតេស្តឈាម។

- **១.៣ វិធីសាស្ត្រនៃការស្រាវជ្រាវ:**

ការប្រមូលទិន្នន័យសំរាប់ការសិក្សាស្រាវជ្រាវត្រូវបានគេសំភាសន៍ជាមួយស្ថាបន័ពាក់ពន្ធ័ ដែលតំណាង មកពីមន្ទីររដ្ឋាភិបាល គ្លីនិចឯកជន និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ដោយប្រើនូវវិធីសាស្ត្រសំភាសន៍ផ្ទាល់មាត់ (មួយទល់មួយ) ដោយមានការប្រើនូវម៉ាស៊ីនថតសំឡេង ក្នុងករណីមានការយល់ព្រមជាមុនពីសាមីសំភាសន៍ ដែលមានបុគ្គលិកម្នាក់ជាអ្នកកត់ត្រា និង ម្នាក់ទៀតជាអ្នកសំភាសន៍ ដែលក្នុងនោះភាគច្រើននៃការសំភាសន៍ បានធ្វើឡើងនៅការិយាល័យរបស់ស្ថាប័នដែលត្រូវសំភាសន៍ ព្រមទាំងមានការណាត់ជាមុនផងដែរ។ លើសពី នេះទៅទៀត វិធីសាស្ត្របែបជាក្រុមពិភាក្សាក៏ត្រូវបានយកមកប្រើ សំរាប់ពលករខ្មែរដែលត្រៀមទៅធ្វើការ នៅក្រៅប្រទេសដោយ ក្នុងនោះមានការប្រើនូវម៉ាស៊ីនថតសំឡេងដើម្បីកត់ត្រានូវពតិមាន ដែលមានការស្នើ សុំការឯកភាពជាមុនពីអ្នកចូលរួម។ វិធីសាស្ត្រនេះមានបុគ្គលិកជាអ្នកកត់ត្រាម្នាក់ និងអ្នកសម្របសម្រួលម្នាក់ ក្នុងការសួរ អ្នកចូលរួម។ ការពិភាក្សាជាក្រុមនេះត្រូវបានធ្វើឡើងនៅមណ្ឌលបណ្តុះបណ្តាលរបស់ក្រុមហ៊ុនជ្រើស រើសពលករ នៅភ្នំពេញ និង ខេត្តបាត់ដំបង។ ម៉្យាងវិញទៀត ភាគច្រើននៃអ្នកចូលរួមនៅក្នុងក្រុមពិភាក្សាមក ពីបណ្តាខេត្តមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្នុងនោះដែរ សំរាប់ការពិភាក្សាជាក្រុមជាមួយ ពលករខ្មែរដែលត្រឡប់មកពីក្រៅប្រទេសត្រូវបានប្រើវិធីសាស្ត្រដូចគ្នានេះដែរ ក្នុងការសំភាសន៍ប៉ុន្តែជាទូទៅ ត្រូវ បានគេធ្វើឡើងតាមបណ្តាខេត្តក្នុងការប្រមូលពតិមាន ដោយកំណត់យកទីតាំងរួមមួយក្នុងការធ្វើក្រុមពិភាក្សា ព្រោះថាពួកគាត់មកពីតាមខេត្តផ្សេងៗគ្នា។ ដោយឡែក ស្ត្រីវៀតណាមដែលធ្វើការនៅក្នុងសេវាកំសាន្តត្រូវបាន សំភាសន៍ដើម្បី ធ្វើករណីសិក្សាសំរាប់ទស្សនៈប្រទេសទទួល។ លើសពីនេះទៅទៀត ការសិក្សាទៅលើ គោល ការណ៏ គោលនយោបាយ ក៏ដូចជាច្បាប់ ផ្សេងៗទៀត ដែលពាក់ពន្ធ័ដោយរួមទាំងកាសែត ទស្សនាវដ្តី និង ឯកសារស្រាវជ្រាវផ្សេងទៀតត្រូវបានយកមកសិក្សាដើម្បីជាជំនួយនិងធ្វើការផ្ទៀងផ្ទាត់ពតិមានដែលប្រមូលបាន។

## ២. ស្ថានភាពប្រទេស

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយដែលស្ថិតនៅក្នុងឧបទ្វីបឥណ្ឌូចិន ដែលមានប្រជាជនប្រហែល ១៥លាន នាក់ (១៣.៨លាននាក់តាមការស្រង់ទិន្នន័យប្រជាជនឆ្នាំ២០០៥) ដែលត្រូវជា ២.២លានគ្រួសារ និងមានភូមិ ១៣៤០៦ នៅក្នុងខេត្ត២៤ ដែលក្នុងនោះ រាជធានីភ្នំពេញមានប្រជាជន៥៧0000នាក់ និងទីប្រជុំជនខេត្ត ក្រុងចំនួនបីផ្សេងទៀត ខេត្តបាត់ដំបង ក្រុងព្រះសីហនុ និង ខេត្តសៀមរាប មានប្រជាជនប្រមាណ ១00000នាក់ ដែលមានចំនួនលើសលប់ ៨៤ភាគរយ ជាអត្រាប្រជាជនលើសលប់ នៅតំបន់ជនបទ និងមានសន្ទស្សន៍ប្រជាជន ១២ ទៅ ១០០ គីឡូម៉ែត្រក្រឡា។ កម្ពុជាគឺជាប្រទេសមួយ ដែលភាគច្រើនកសិករ ប្រកបរបបកសិកម្មដែលមាន ៧៣ភាគរយនៃប្រជាជនសរុប (យោងតាម Asian Migrant Center, 2002) ភាពក្រីក្រគ្មានដីធ្លី និងគ្រោះធម្មជាតិរួមមាន ភាពរាំងស្ងួត និងទឹកជំនន់ បានជំរុញអោយមានការធ្វើចំណាកស្រុកស្វែងរកការងារនៅទីប្រជុំជននានា ក៏ដូចជាទៅប្រទេសជិតខាងផងដែរ។

ក្នុងនោះកត្តាជំរុញមួយចំនួនទៀតដូចជា បំណុល និង កសិផលនៅក្នុងសហគមន៍ដែលជំរើសមួយទៀតសំរាប់ពួកគេក្នុងការធ្វើចំណាកស្រុក។ ម្យ៉ាងវិញទៀត ក៏មានកត្តាទាក់ទាញពីប្រទេសទទួលមួយចំនួនដូចជា ថៃ ម៉ាឡេស៊ី និង សាធារណៈរដ្ឋកូរ៉េ ដែលមានតំរូវការការងារមិនមានជំនាញ ដែលស្ថិតនៅក្នុងប្រភេទការងារបីរួមមាន ប្រភេទការងារគ្រោះថ្នាក់ ការងារមិនមានជំនាញ និង ការងារដែលធ្វើអោយប៉ះពាល់សុខភាព។ ក្តីសង្ឃឹមពី ការងារបង់កំរៃ និង ការស្វែងរកនូវស្ថានភាពមួយប្រសើរជាងមុននេះហើយដែលជាកត្តាធ្វើឱ្យពួកគេចំណាកស្រុកទៅប្រទេសជិតខាង ដែលក្នុងនោះក៏រួមបញ្ចូលនូវបណ្តាញដែលមានស្រាប់ និងភ្នាក់ងារកណ្តាលដែលជួយសម្របសម្រួលក្នុងការជ្រើសរើស និងបញ្ជូនទៅធ្វើការនៅប្រទេសផ្សេងទៀតផងដែរ។
លើសពីនេះទៅទៀត ប្រទេសកម្ពុជាបានបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ចាប់តាំងពីឆ្នាំ ១៩៩៨ ដល់ ឆ្នាំ ២០០៧ បានចំនួន ៨៩៦៩នាក់ តាមរយៈក្រុមហ៊ុនជ្រើសរើសពលករចំនួនពីរ ដែលក្នុង នោះមាន ៧០៤២នាក់ជាស្ត្រី និង ៤៣៤៨នាក់ធ្វើការជំនួយការនៅក្នុងផ្ទះ ដែលបាននាំមកនូវចំណូលលល ប្រមាណ ១៣00000ដុល្លាសហរដ្ឋអាមេរិចជារៀងរាល់ឆ្នាំ។ ចាប់តាំងពីឆ្នាំ ២០០៣ រហូតមកទល់ពេលនេះ ពលករខ្មែរ ៣៣៩៩នាក់ ត្រូវបានបញ្ជូនទៅធ្វើការនៅសាធារណៈរដ្ឋកូរ៉េ ដែលមាន ៤៦៨នាក់ជាពលករស្ត្រី អាចនាំចំណូលប្រចាំឆ្នាំ ៨ ១៥០ 000 ដុល្លាសហរដ្ឋអាមេរិច។ ដោយឡែក ពលករចំណាកស្រុកមិនមានឯកសារ គ្រប់គ្រាន់/ខុសច្បាប់ ចំនួន ៣៧ ១៤២នាក់ ត្រូវបានគេសម្របសម្រួលដោះស្រាយដើម្បីធ្វើអោយពួកគេក្លាយជាពលករស្របច្បាប់/មានឯកសារ នៅក្នុងចំណោមពលករ ១៨០ 000នាក់ នៅប្រទេសថៃ នៅឆ្នាំ ២០០៦

រហូតមកទល់ ពេលបច្ចុប្បន្ន និង ក្នុងនោះដែរ ពលករចំណាកស្រុកខ្មែរចំនួន ២៥០៨នាក់ ត្រូវបានបញ្ជូនទៅធ្វើនៅប្រទេសថៃ បន្ថែមទៀតតាមរយៈក្រុមហ៊ុនជ្រើសរើសពលករ ដែលក្នុងនោះមាន ៧០៨ នាក់ជាស្ត្រី ។

ម៉្យាងវិញទៀត កម្ពុជាជាប្រទេសបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេស ថៃ ម៉ាឡេស៊ី និង សាធារណៈរដ្ឋកូរ៉េ នៅក្នុងវិស័យរោងចក្រ សហគ្រាស ភោជនីយដ្ឋាន អ្នកជំនួយការតាមផ្ទះ និង ចំការដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសដោយយោងទៅលើអនុក្រឹត្យលេខ ៥៧ ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស។ ក្នុងនោះដែរ ប្រទេសកម្ពុជាបានចុះអនុស្សារណៈយោគយល់គ្នា ក៏ដូចជាកិច្ចព្រមព្រៀងទ្វេភាគីដទៃទៀតជាមួយប្រទេសមួយចំនួន ដែលមាត្រាក៏ដូចជា ខ មួយចំនួនទៀតតំរូវអោយបំពេញដោយភាគីកម្ពុជា ដែលក្នុងនោះរួមមាន ការពិនិត្យសុខភាព ការធ្វើតេស្តឈាមរកមេរោគអេដស៍ រោគថ្លើម និង ប្រភេទជំងឺសំខាន់មួយចំនួនទៀតដែលកំនត់ដោយប្រទេសទទួល។

លើសពីនេះទៅទៀត មុនពេលបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេសក្រុមហ៊ុនដែលកំពុងប្រតិបត្តិការ និងមានការទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈគឺតំរូវអោយមានការពិនិត្យសុខភាព និងធ្វើតេស្តឈាមរកមេរោគអេដស៍/ជំងឺអេដស៍ និង ថ្លើមដែលធ្វើឡើងដោយនាយកដ្ឋានពេទ្យការងារ បន្ទាប់ពីបានជ្រើសរើសពលករដើម្បីបំពេញទៅតាមលក្ខខ័ណរបស់ប្រទេសទទួល។ ខាងក្រោមជាប្រភេទជំងឺដែលត្រូវបានធ្វើតេស្តដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានដូចជាៈ **រោគអេដស៍/ ជំងឺអេដស៍ មេរោគរបេង មេរោគគ្រុនចាញ់ ជំងឺឃ្លង់ ជំងឺឆ្កួតជ្រូក ជំងឺរវើរវាយ ជំងឺកាមរោគ រោគទងសួត ជំងឺបេះដូង ជំងឺលើសឈាម ជំងឺថ្លង់ ជំងឺទឹកនោមផ្អែម រោគក្រពះ ជំងឺក្រលៀន ជំងឺមហារីក រោគថ្លើម។**

ដោយឡែក មណ្ឌលផ្តល់ប្រឹក្សា និង ការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយរក្សាការសម្ងាត់ មាន១២៥កន្លែង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលផ្តល់សេវាមិនគិតប្រាក់កំរៃសំរាប់អតិថិជនដែលស្ម័គ្រចិត្តធ្វើតេស្តឈាមរក មេរោគអេដស៍/ជំងឺអេដស៍ ដែលមណ្ឌលទាំងនោះរួមបញ្ចូលទាំងសេវារបស់អង្គការក្រៅរដ្ឋាភិបាលផងដែរ។ ចាប់តាំងពី ខែ មករា ដល់ខែ មិថុនា ឆ្នាំ ២០០៦ មានអតិថិជន ៩៩១០២នាក់ដែលបានទទួលសេវាការផ្តល់ប្រឹក្សាមុនធ្វើតេស្ត ក្នុងនោះមាន ៨៨៥៧នាក់ បានបង្ហាញថាលទ្ធផលវិជ្ជមាន និង ២២៣០នាក់មានលទ្ធផលអវិជ្ជមាន និង ៩៨៧៥៦នាក់មានលទ្ធផលមិនច្បាស់លាស់ ព្រមទាំង ៩៦៤៥៤នាក់ទទួលសេវាផ្តល់ប្រឹក្សាក្រោយការធ្វើតេស្ត (យោងទៅលើរបាយការណ៏របស់មជ្ឈមណ្ឌលជាតិ សើរស្បែក កាមរោគ និងជំងឺអេដស៍ ជំហ៊ានទី ១ ខែ មករា ដល់ ខែ មិថុនា ២០០៦)។ ម៉្យាងវិញទៀត ការផ្តល់ប្រឹក្សា និងការធ្វើតេស្តគឺជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្ត្របង្ការមេរោគអេដស៍/ជំងឺអេដស៍ និងការថែទាំ សំរាប់ហេតុផល និង ទំរង់

ផ្សេងៗទៀត *(យោលទៅលើគោលការណ៍ គោលនយោបាយ និងយុទ្ធសាស្ត្រសំរាប់ការផ្តល់ប្រឹក្សា និងការធ្វើតេស្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា បោះពុម្ព លើកទី ២ ខែ កញ្ញា ២០០៤ ដោយ មជ្ឈមណ្ឌលជាតិ សើរស្បែក កាមរោគ និងជំងឺអេដស៍)*។

## ៣. ការបង្ហាញពីលទ្ធផលនៃការវិភាគ

- **៣.១ មុនពេលធ្វើដំណើរ**

  - **៣.១.១ នីតិវិធីនៃការធ្វើតេស្ត**

ព្រះរាជាណាចក្រកម្ពុជាមានច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ដែលបានអនុម័តដោយសភាជាតិនៅថ្ងៃ ១៤ ខែមិថុនា ឆ្នាំ២០០២។ ច្បាប់នេះមានវិធានការដើម្បីបង្ការ និងការពារការរីករាលដាល មេរោគអេដស៍/ជំងឺអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលច្បាប់នេះមាន ១១ ជំពូក និង ៥៣ មាត្រា ដែលគ្របដណ្តប់លើបញ្ហាអេដស៍ ដែលរួមបញ្ចូលការធ្វើតេស្តឈាមដោយស្ម័គ្រចិត្តផងដែរ។ លើសពីនេះទៅទៀត មជ្ឈមណ្ឌលជាតិ សើរស្បែក កាមរោគ និងជំងឺអេដស៍ បានបង្កើតនូវគោលការណ៍មួយចំនួនដូចខាងក្រោម:

- គោលការណ៍ជាតិសំរាប់ការជ្រើសរើសអ្នករស់នៅជាមួយមេរោគអេសដ៏/ជំងឺអេដស៍ ក្នុងការប្រើឱសថប្រឆាំងមេរោគអេដស៍ ខែកក្កដា ២០០៧
- គោលការណ៍ជាតិស្តីពីការប្រើប្រាស់ឱសថប្រឆាំងមេរោគអេសដ៏សំរាប់ពេញវ័យ និងជំទង់ ខែធ្នូ ឆ្នាំ ២០០៣
- គោលការណ៏សំរាប់ការបង្កើតមណ្ឌលផ្តល់ប្រឹក្សា រក្សាការសំងាត់ និង ធ្វើតេស្តឈាមរកមេរោគអេដស៍/ជំងឺអេដស៍ដោយស្មគ្រ័ចិត្ត ខែធ្នូ ឆ្នាំ២០០៤

កម្ពុជាជាប្រទេសបញ្ជូន ឆ្លងកាត់ និង ប្រទេសទទួល ដែលបានបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេស ថៃ ម៉ាឡេស៊ី និង សាធារណៈរដ្ឋកូរ៉េ តាមរយៈក្រុមហ៊ុនស្របច្បាប់ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះដែរ យោងអនុក្រឹត្រលេខ ៥៧ ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស ចុះហត្ថលេខាថ្ងៃ ២០ ខែកក្កដា ឆ្នាំ ១៩៩៥ បានតំរូវអោយបេក្ខជនត្រូវបំពេញទៅតាមលក្ខ័ខ័ណ្ឌនៃប្រទេសទទួល និង ប្រទេសបញ្ជូនដែលមានដូចខាងក្រោម:

- បេក្ខជនត្រូវមានប្រវត្តិរូបដោយមានរូបថតភ្ជាប់
- បេក្ខជនត្រូវមានលិខិតថ្កោលទោស
- លិខិតបញ្ជាក់ពីសុខភាពដែលចេញដោយនាយកដ្ឋានពេទ្យការងារ
- សេចក្តីចំលងនៃវិញ្ញាបនត្រ័ ឬសញ្ញាបត្រ័ប្រសិនបើមាន
- ពាក្យសុំការងារ

ដោយយោងទៅលើការសំភាសន៏ដាច់ដោយឡែកពីគ្នាជាមួយស្ថាបន័ពាក់ពន្ធ័មួយចំនួនដូចជា មន្ទីរពេទ្យព្រះសីហនុ (អតីតពេទ្យសហពន្ធ័រុស្សី) នាយកដ្ឋានពេទ្យការងារ មន្ទីរពេទ្យព្រះកេតុមាលា និងមន្ទីរពេទ្យព្រះកុសមៈ ដើម្បីស្វែងយល់ថាតើមានស្ថាប័នណាខ្លះដែលបានធ្វើតេស្តឈាមដល់ពលករខ្មែរមុននឹងបញ្ជូនទៅធ្វើការនៅប្រទេសក្រៅ ហើយដែលភាគច្រើនពួកគេត្រូវបានធ្វើតេស្តរកមេរោគអេសដ៏ ថ្លើមប្រភេទ អា បេ សេ ជំងឺកាមរោគ អេកូសាស្ត្រសំរាប់រោគរបេង និង ប្រភេទជំងឺមួយចំនួនទៀតដែលតំរូវដោយប្រទេសទទួល។ ក្នុងនោះដែរ ភាគច្រើននៃស្ថាប័នពាក់ពន្ធ័ខាងលើបានចូលរួមក្នុងដំណើរការពិនិត្យសុខភាព ក៏ដូចជាធ្វើតេស្តដល់ពលករខ្មែរមុនទៅធ្វើការនៅក្រៅប្រទេស ដែលត្រូវបានបញ្ជូនទៅធ្វើតេស្តដោយក្រុមហ៊ុនជ្រើសរើសពលករ។

> *តេស្តឈាមកាលនោះគេយកមកគេធ្វើតេស្តមួយ ទី១ថតសួត ដើម្បីមើលរបេង ទី២យើងមើលអេដស៍ ទី៣យើងមើលអេរីទិតហើយនឹងជំងឺគ្រុនចាញ់មើលឈាម។ យើងធ្វើច្រើនទៅតាមប្រទេសដែលទទួល (មន្ត្រីនៃមន្ទីរពេទ្យសហពន្ធ័រុស្សី ក្រុងភ្នំពេញ)។*

តួយ៉ាង ក៏មានការពិភាក្សាដាច់ដោយឡែកជាមួយក្រុមហ៊ុនជ្រើសរើសពលករដែលកំពុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន និង មានការទទួលស្គាល់ដោយរាជរដ្ឋាភិបាលក្នុងការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី រួមមាន ក្រុមហ៊ុន ស៊ី អិល អេស សាខាមណ្ឌលអេលីត ក្រុមហ៊ុន វី ស៊ី និងក្រុមហ៊ុនហ្វីលីម័រ បានបញ្ជាក់អោយដឹងថា ពលករខ្មែរត្រូវបានគេតំរូវអោយធ្វើតេស្តរកមេរោគអេដស៏ ថ្លើម ជំងឺកាមរោគ ប្រមេះ ពិនិត្យទឹកនោម និង ថតសួតដើម្បីបំពេញនូវលក្ខខណតំរូវសំរាប់ការទៅធ្វើការនៅក្រៅប្រទេស ដែលពលករភាគច្រើនមកពីតាមបណ្តាខេត្តនានាដែលត្រូវបានបញ្ជូនទៅធ្វើតេស្តដោយក្រុមហ៊ុនជ្រើសរើសពលករ។

> *ជាទូទៅទាំងពលករ ពលការិនី ធ្វើការនៅ តាមផ្ទះក្តី តាមរោងចក្រក្តី ទី១ សាម៉ីខ្លួន ត្រូវពិនិត្យឈាម ការពិនិត្យឈាមគេពិនិត្យទៅលើបញ្ហា សំខាន់ៗ ៣គឺ ទី១កាមរោគ ទី២អេដស៍និងទី៣ ថ្លើម សំខាន់គឺជំងឺ៣នេះក្រោយពីជាប់ហើយយើងថាអាចទទួលយកបានក្រោយរយៈ៣ថ្ងៃទៅមួយអាទិត្យ បានយើងទៅពិនិត្យនៅពេទ្យធំ ហៅថាពិនិត្យទូទៅ មានច្រើនណាសគឺ ថតសួត ថ្លើម ឈាមមើលឡើងវិញទាំងអស់មើលទាំងទឹកនោមនេះជាចំណុចចុងក្រោយជាក់ស្តែង ដែលនៅពេលគាត់ស្នាក់នៅរៀនសូត្ររៀងរាល់មួយខែ ម្តងយើងពិនិត្យទឹកនោម សំរាប់ស្ត្រីជៀសវាងគាត់មានផ្ទៃពោះ ជួនកាលគាត់មកថ្ងៃដំបូង មើលអត់ទាន់ដឹង មួយអាទិត្យក៏អត់ដឹងដែរ មួយខែយើងមើលរៀងរាល់ពេល ឱ្យអស់ចិត្តគឺមុនពេលគាត់ចេញដំណើរ។ នេះគឺជាគោលការណ៏ ដែលខាងក្រុមហ៊ុនខ្ញុំធ្វើកន្លងមកក៏ដូចជាសាម៉ីខ្លួនជាពិសេសពលការនីពេលដែលគាត់ទៅដល់ម៉ាឡេខាងនោះគេបានធ្វើម្តងទៀតមុននឹងនិយោជក ដែលជា*

*ថៅកែមកយកគាត់នេះគឺជាគោលការណ៍រួមដែលយើងធ្វើកន្លងមក ( ក្រុមហ៊ុនជ្រើសរើសពលករ ហ្វីលីម័រ នៅកម្ពុជា) ។*

ដោយយោងទៅលើលទ្ធផលលនៃការពិភាក្សាជាក្រុម និង ការសំភាសន៍ពលករចំណាកស្រុក មួយទល់មួយជាមួយពលករដែលត្រៀមទៅធ្វើការនៅប្រទេសថៃ និង ម៉ាឡេស៊ី បានបង្ហាញអោយដឹងថា ពួកគេត្រូវបានគេប្រាប់ពតិមានស្តីពីការធ្វើតេស្តសុខភាពជាមុន មុននឹងត្រូវបានគេបញ្ជូនទៅភ្នាក់ងារកណ្តាលរបស់ក្រុមហ៊ុនជ្រើសរើសពលករ ឬ ការិយាល័យសាខាតាមបណ្តាខេត្តរបស់ក្រុមហ៊ុន ដែលពួកគេភាគច្រើនបានយល់ព្រមពីបញ្ហានៃការពិនិត្យសុខភាពនេះ ក៏ដូចជាការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយសារពួកគេត្រូវការការងារ ដើម្បីទទួលបានប្រាក់មកជួយផ្គត់ផ្គង់នៅក្នុងគ្រួសាររបស់ពួកគេ។ ក្នុងនោះដែរ ទាក់ទងនឹងនីតិវិធីនៃការធ្វើតេស្ត និង ដោយសារភាពខុសគ្នានៃថ្លៃសំរាប់ការធ្វើតេស្ត ទើបក្រុមហ៊ុនធ្វើការទំនាក់ទំនងជួលវេជ្ជបណ្ឌិត ឬគ្រូពេទ្យ ឬគ្លីនិច ឯកជន ក៏ដូចជា មន្ទីរពេទ្យផ្សេងទៀតដើម្បីធ្វើតេស្តឈាមរកមេរោគអេដស៍ រោគថ្លើម របេង និង ពិនិត្យទឹកនោម មុននឹង បញ្ជូនទៅពិនិត្យសុខភាព និងធ្វើតេស្តឈាមរកមេរោគអេដស៍នៅនាយកដ្ឋានការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ម៉្យាងវិញទៀត តាមរយៈនៃការសំភាសន៍ជាមួយពលករបានបញ្ជាក់អោយដឹងថា ពួកគេត្រូវបានគេធ្វើតេស្តឈាមរកមេរោគអេដស៍ រោគថ្លើម ថតសួត ពិនិត្យទឹកនោម ពិនិត្យភ្នែក ត្រចៀក និង ប្រភេទជំងឺ មួយចំនួនទៀត ។ល។

ដោយឡែក លក្ខខណ្ឌតំរូវរបស់ប្រទេសទទួល និង ការធ្វើតេស្តឈាមរកមេរោគអេដស៍ ដែលធ្វើឡើងចំពោះពលករចំណាកស្រុកមុននឹងត្រូវបានគេបញ្ជូនទៅធ្វើការនៅក្រៅប្រទេស ដែលវាជាការប្រាសចាកទៅនឹងច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍អេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

- **៣.១.១.១ ការយល់ព្រមជាមុន**

ដោយយោងទៅលើ ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ត្រង់ ជំពូកទី៤ មាត្រាទី ១៩ ចែងថា *ការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងត្រូវមានការយល់ព្រមជាមុនពីសាម៉ីជនផ្ទាល់។ ចំពោះសាម៉ីជនជាអនីតិជន តម្រូវឱ្យមានការយល់ព្រមជាលាយលក្ខអក្សរពីអាណាព្យាបាលស្របច្បាប់។ បើយល់ព្រមជាលាយលក្ខអក្សរពី អាណាព្យាបាលស្របច្បាប់ពុំអាចធ្វើទៅបាន ការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍អាចប្រព្រឹត្តិទៅបានដោយគ្រាន់តែមានការព្រម*

*ព្រៀងពីអទីតិជន ប្រសិនបើការធ្វើតេស្តនេះ ផ្តល់ផលប្រយោជន៍ផ្ទាល់ចំពោះអទីតិជននោះ ។ ចំពោះជនវិលកចរិត វដ្តត្រូវយក ចិត្តទុកដាក់ ។*

ទោះបីជាយ៉ាងណាក៏ដោយ មន្ត្រីតំណាងមកពីនាយកដ្ឋានពេទ្យការងារបានបញ្ជាក់ថា " *បើនិយាយពីការស្ម័គ្រចិត្តគឺ ១០០ភាគរយព្រោះគាត់ចង់ទៅធ្វើការហើយប្រទេសគេតំរូវបែបនេះ ការមកគាត់ មិនប្រកែកទេ ហើយគាត់ដឹងថាមកមើលអីទៀតផង* "

ដូចនេះមានន័យថា លក្ខខណ្ឌតំរូវរបស់ប្រទេសទទួលមានលក្ខណៈផ្ទុយពីច្បាប់នៅប្រទេសបញ្ជូន ។ ថ្វីបើដូច្នេះក៏ដោយ ភាគច្រើននៃពលករខ្មែរដែលស្វែងរកការងារធ្វើនៅប្រទេសក្រៅមានដូចជា ប្រទេសថៃ ម៉ាឡេស៊ី និង សាធារណៈកូរ៉េ ត្រូវបានគេប្រាប់ជាមុនដោយក្រុមហ៊ុនជ្រើសរើសពលករ ឬភ្នាក់ងារកណ្តាលនៅតាមសហគមន៏របស់ពួកគេស្តីការធ្វើពិនិត្យសុខភាពដែលរួមមានតេស្តឈាមរកមេរោគអេដស៏ ថ្លើម របេង និង ប្រភេទជំងឺមួយចំនួនទៀត ដែលបញ្ហានេះត្រូវបានទទួលការយល់ព្រមពីពលករដោយសារតែតំរូវការការងារដើម្បីបានចំណូលផ្គត់ផ្គង់នៅក្នុងគ្រួសារ ។

### ♦ ៣.១.១.២ ការផ្តល់ប្រឹក្សាមុន និង ក្រោយការធ្វើតេស្ត

ក្នុងនោះដែរ ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាល មេរោគអេដស៏/ជំងឺអេដស៏ ត្រង់មាត្រាទី២៤ ចែងថា *គ្រប់កន្លែងធ្វើតេស្តមេរោគអេដស៏/ជំងឺអេដស៏ ត្រូវផ្តល់កិច្ចប្រឹក្សាមុន និងក្រោយការធ្វើតេស្តដល់ជនដែលមកសុំធ្វើតេស្តមេរោគអេដស៏/ជំងឺអេដស៏ ។ អ្នកផ្តល់កិច្ចប្រឹក្សានេះត្រូវមានសមត្ថភាពគ្រប់គ្រាន់ សមស្របតាមស្តង់ដាកំណត់ដោយក្រសួងសុខាភិបាល*។ លើសពីនេះការផ្តល់ប្រឹក្សាមុន និងក្រោយការធ្វើតេស្ត ត្រូវមានចំនុចដូចខាងក្រោម:

- ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត
    - ពិភាក្សាពីហេតុផលដែលស្នើសុំការធ្វើតេស្ត ។
    - វាយតំលៃពីការយល់ដឹងរបស់អតិថិជនទាក់ទងនឹងពត៏មានអេដស៏/ជំងឺអេដស៏ ។
    - វាយតំលៃពីគ្រោះថ្នាក់របស់អតិថិជនចំពោះមេរោគអេដស៏ ។
    - ពិភាក្សាពីជំរើសដ៏ល្អបំផុតរបស់អតិថិជន និងផែនការកាត់បន្ថយការគ្រោះពីមេរោគអេដស៏ ។
    - ពន្យល់ដល់អតិថិជនពីអត្ថន័យនៃទំនាក់ទំនងលទ្ធផលវិជ្ជមាន និងអវិជ្ជមាន ដោយរួមបញ្ចូលទាំងរយៈពេលនៃការមានរដូវផងដែរ ។

- ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត ( លទ្ធផលអវិជ្ជមាន)
    - ការផ្តល់នូវលទ្ធផល និងពិភាក្សាពីអត្ថន័យ និងការទាក់ទងរបស់វា
    - ពិភាក្សាពីលទ្ធផល និងសង្ខេបពីផែនការសំរាប់កាត់បន្ថយភាពគ្រោះថ្នាក់ដោយរួមមានការផ្តល់នូវប្រឹក្សា
    - ផែនការសំរាប់ការធ្វើតេស្តបន្ថែមទៀតនៅពេលវេលាសមស្របណាមួយ
- ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត ( លទ្ធផលវិជ្ជមាន)
    - ការប្រាប់ពីលទ្ធផលតេស្ត និងអត្ថន័យរបស់វា
    - ធានាឱ្យប្រាកដថាអតិថិជនអាចរៀនសូត្រដើម្បីដោះស្រាយនូវស្ថានភាពរបស់អតិថិជន
    - ពិភាក្សាពីអារម្មណ៏របស់អតិថិជន និង ការរំជួលចិត្ត
    - ការរំជួលចិត្ត និងការគាំទ្រផ្នែកចិត្តសាស្ត្រ
    - ពិភាក្សាពីទំនាក់ទំនងលៃទ្ធផលតេស្តរបស់អតិថិជន
    - ពិភាក្សាពីការព្រួយបារម្ភនិងការភ័យខ្លាចរបស់អតិថិជន
    - ប្រឹក្សាពីការដោះស្រាយបញ្ហាបន្ទាន់ និងការដែលត្រូវអនុវត្ត
    - ប្រឹក្សាពីការរស់នៅ និងដោះស្រាយជាមួយមេរោគអេដស៏
    - ធ្វើការផ្តល់ពតិមានពីការរស់នៅឱ្យមានសុខភាពល្អ
    - ធ្វើការផ្តល់ពតិមានពីការទទួលឱសថ/ផ្តល់ប្រឹក្សា/សេវាគាំទ្រ ដែលការផ្តល់ប្រឹក្សាវាមានសារៈសំខាន់សំរាប់ឱ្យអតិថិជនអាចដោះស្រាយបញ្ហារបស់គេបាន។

ទោះបីជាយ៉ាងណាក៏ដោយ មន្ត្រីរដ្ឋាភិបាលភាគច្រើននៃមន្ទីរពេទ្យមួយចំនួនដែលបានផ្តល់ការសំភាសន៏បានបញ្ជាក់អះអាងស្រដៀងគ្នាថា អ្នកផ្តល់ប្រឹក្សាបានបំពេញតាមតួនាទី និងភារកិច្ចរបស់ពួកគេទៅតាមអ្វីដែលច្បាប់បានចែង នោះមានន័យថារាល់ពលករ រាល់អតិថិជន ក៏ដូចជាពលករចំណាកស្រុកទាំងអស់ត្រូវបានផ្តល់ប្រឹក្សាមុន និងក្រោយការធ្វើតេស្ត។ តួយ៉ាង មន្ត្រីមកពីអង្គការក្រៅរដ្ឋាភិបាលដែលជាអ្នកផ្តល់ប្រឹក្សាពីការធ្វើតេស្តឈាមរកមេរោគអេដស៏ បានអះអាងស្រដៀងគ្នានេះដែរថា រាល់ការធ្វើតេស្តរកមេរោគអេដស៏គឺធ្វើទៅតាមគោលការណ៏ស្មគ្រ័ចិត្តដោយមានផ្តល់នូវប្រឹក្សាមុន និងក្រោយការធ្វើតេស្តផងដែរ បើយោងទៅលើការសំភាសន៏។

*ខាងអ្នកផ្តល់ប្រឹក្សាជា អ្នកធ្វើជំនាញរបស់គេ មុន និងយើងអោយអ្នកផ្តល់ប្រឹក្សា យើងធ្វើតេស្តសិន ក្រោយពេលដឹងថាវិជ្ជមានហើយ គឺតាមដាក់ស្តែងហើយ អ្នកខ្លះមានវិជ្ជមានគឺមានរោគសើរស្បែក ហើយយើងអោយគាត់ទៅពិនិត្យរោគសើរស្បែក ហើយយើងផ្តល់គាត់មានអោយ គាត់ទៅកន្លែងខ្លះ ដែលគេផ្តល់ ARV ។ ហើយអ្នកខ្លះបើគាត់មានលក្ខណៈក្អកអញ្ជើងយើងឱ្យគាត់ទៅកន្លែងព្យាបាល (មន្ត្រីនៃមជ្ឈមណ្ឌលជាតិជំងឺសើរស្បែក និងកាមរោគ ភ្នំពេញ) ។*

*តេស្តឈាមរក្សាការ សំងាត់ ផ្តល់ថ្នាំពន្យាពីម្តាយទៅកូនប៉ុន្តែយើងមាន បណ្តាញដែលគេទទួលរឿងហ្នឹង។ យើងមានការធ្វើ តេស្តឈាមគ្រប់អតិថិជន ទាំងពីរភេទមិនថាស្ត្រីមានផ្ទៃពោះ ហើយការធ្វើតេស្តឈាមមិន មើលតែ HIV មួយមុខទេមានមើល ដូចជាស្វាយ ថ្លើមជាដើម ក្រៅពីសេវានិងការពិនិត្យរោគស្ត្រី មើលដុំ សាច់ស្បូន និង STI ទាំងពីរភេទបើគាត់ មានបញ្ហាណាមួយនៃរោគស្ត្រីយើងធ្វើការបញ្ជូនបន្តទៅកាន់ពេទ្យធ្វើការពិនិត្យ ។ ក្រៅពីការមើលរោគយើងមានការថែទាំផ្ទៃពោះមុនពេល សំរាល ហើយមានផ្តល់ជាវ៉ាក់សាំងដូចជាតេតានុស រលាកស្រោមខួរ ។ល។ ការមើលថៃមុន និងក្រោយសំរាលក្រៅ ពីហ្នឹងមានការមើល ទៅលើលំហាត់ប្រាណ មួយទៀតគឺការផ្តល់ប្រឹក្សាយោបល់ចំពោះ គូរភរិយាថ្មីដែលត្រៀមរៀបការក្រៅពីនេះ មានការទទួលមើលស្រី ដែលត្រូវគេចាប់រំលោភផ្សេងទៀត (បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល រ៉ាក់ ភ្នំពេញ) ។*

ដោយឡែក យោងតាមការសំភាសន៏ជាមួយស្ថាប័នដែលពាក់ពន្ធ័មកពីក្រុមហ៊ុនជ្រើសរើសពលករបានរកឃើញថា ដំណើរការនៃការផ្តល់ប្រឹក្សាមុន និង ក្រោយការធ្វើតេស្តឈាមរកមេរោគដែលតំរូវដោយប្រទេសទទួលកម្រនឹងបានអនុវត្តន៏ដោយក្រុមវេជ្ជបណ្ឌិត/គ្រូពេទ្យ ដែលបានត្រូវបានជួលដោយក្រុមហ៊ុនជ្រើសរើសពលករដើម្បីធ្វើតេស្តរកមេរោគអេដស៏ ថ្លើម របេង និង ប្រភេទជំងឺមួយចំនួនទៀត ព្រោះពួកគាត់ភាគច្រើនជាអ្នកទទួលខុសត្រូវ ខាងបន្ទប់ពិសោធន៏រកមេរោគអេដស៏មិនមែនជាអ្នកជំនាញខាងផ្នែកផ្តល់ប្រឹក្សានោះឡើយ។ តំលៃថោកគឺជាហេតុផលមួយដែលក្រុមហ៊ុនជ្រើសរើសពលករសំរេចចិត្តធ្វើតេស្តជាមុនទាក់ទងនឹងជំងឺ អេដស៏ ថ្លើម និងពិនិត្យទឹកនោម ដើម្បីរកថាមានផ្ទៃពោះ ឬយ៉ាងណា មុននឹងធ្វើការបញ្ជូនទៅពេទ្យការងារដែលមានការទទួលស្គាល់ពីប្រទេសទទួល។

*មិនដែលមានប្រាប់ពត័មានទេគឺទៅចាប់ផ្តើមពិនិត្យឈាម និងទឹកនោមតែម្តង (ក្រុមហ៊ុនជ្រើសរើសពលករ អេលីត ភ្នំពេញ) ។*

*ជាទូទៅខាងក្រុមហ៊ុនយើងខ្ញុំជាអ្នកផ្ដល់ព័តមានឧទាហរណ៍ថាខាងសាម៉ី ខ្លួនគាត់មកសួរព័តមានចង់ទៅធ្វើការនៅម៉ាឡេរ៉ីថៃ ត្រូវធ្វើកិច្ចសន្យា ប្រាក់ខែប៉ុន្មានណាត្រូវកាត់សងប៉ុន្មាន ប៉ុន្តែមុននិង អ្នកទៅត្រូវពិនិត្យ ឈាមសិនដោយក្រុមហ៊ុនជាអ្នកចេញ ជូនលទ្ធផលជាប់ រឺធ្លាក់វាជាសំណាងរបស់យើងជាទូទៅពេលគាត់មកដល់តែងតែណែនាំថាពេលដែលបូមឈាមវាមិនមានការប៉ះពាល់គ្រាន់តែបូមប៉ុន្មានសេសេតែប៉ុណ្ណោះ (បុគ្គលិកក្រុមហ៊ុនជ្រើសរើសពលករ ហ្វីលីម័រ ភ្នំពេញ) ។*

ក្នុងនោះដែរ ផ្អែកតាមការសំភាសន៏មួយទល់មួយ និង ជាក្រុមជាមួយពលករខ្មែរដែលត្រៀមទៅធ្វើការនៅប្រទេសម៉ាឡេស៊ីជាជំនួយការតាមផ្ទះ និង នៅប្រទេសថៃក្នុងវិស័យរោងចក្របានបញ្ជាក់អោយដឹងថា ពួកគេភាគច្រើនមិនត្រូវបានគេផ្ដល់ប្រឹក្សាមុន និង ក្រោយការធ្វើតេស្ដឈាមរកមេរោគនោះទេ បើទោះបីជាលក្ខខណ័តំរូវមួយចំនួនទៀតពីប្រទេសទទួលក៏ដោយ។ លើសពីនេះទៅទៀត ការធ្វើតេស្ដដែលត្រូវបានធ្វើដោយ វេជ្ជបណ្ឌិត ឬគ្រូពេទ្យដែលជួលដោយក្រុមហ៊ុនជ្រើសរើស ពលករក្នុងគោលបំណងកាត់បន្ថយការចំណាយរបស់ ក្រុមហ៊ុន មុននឹងធ្វើការបញ្ជូនទៅពិនិត្យសុខភាព ក៏ដូចជាការ ធ្វើតេស្ដឈាមរកមេរោគអេដស៏ដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល ក៏ដូចជាប្រទេសទទួលផងដែរ ដែលនីតិវិធីនៃការធ្វើតេស្ដ របៀបនេះ មានការនិយមពីក្រុមហ៊ុនជ្រើសរើសពលករនៅក្នុងប្រទេសកម្ពុជាព្រោះថាពួកគេអាចដឹងពីលទ្ធផលនៃការធ្វើតេស្ដសុខភាពពលករជាមុន មុនសំរេចថាទទួលពលករអោយស្នាក់នៅ ឬក៏អត់។

នៅក្នុងបរិបទនៃដំណើរការជ្រើសរើសពលករនៅប្រទេសកម្ពុជា ពលករត្រូវបានគេធ្វើតេស្ដឈាម និង ទឹកនោម រកមេរោគអេដស៏ ថ្លើម និងការមានផ្ទៃពោះមុនពេលអនុញ្ញាត្តិអោយស្នាក់នៅមណ្ឌលបណ្ដុះបណ្ដាលរបស់ក្រុមហ៊ុន ដើម្បីទទួលការហ្វឹកហ្វាត់ទាក់ទងនឹងការដែលខ្លួនត្រូវទៅធ្វើការនៅប្រទេសទទួល។ ដោយឡែកពលករជារឿយៗដែលទៅធ្វើការនៅប្រទេសម៉ាឡេស៊ីជាជំនួយនៅក្នុងផ្ទះ ត្រូវបានគេតំរូវអោយស្នាក់នៅក្នុងមណ្ឌលរបស់ក្រុមហ៊ុនរយៈពេលពី ៣ខែ ទៅ ៦ខែ ក្នុងករណីលទ្ធផលតេស្ដឈាមបង្ហាញថាអវិជ្ជមាន។

*ថាអាចមានជំងឺអេដស៏ និងប្រហែលមួយនាទីអាចដឹងលទ្ធផល ពេទ្យអត់មានណែនាំទេប្រហែល មួយកំណាត់ថ្ងៃដឹងលទ្ធផលប្រហែល៣ម៉ោង (ពលករដែលត្រៀមទៅធ្វើការនៅប្រទេសម៉ាឡេស៊ី) ។*

*មិនប្រាប់អីទេ គ្រាន់តែទៅជួបម្ដងម្នាក់ កាលខ្ញុំទៅមានគ្នា១០នាក់ (ពលករត្រលប់មកពីប្រទេសម៉ាឡេស៊ី) ។*

*មិនដែលមានប្រាប់ព័ត៌មានទេគឺទៅចាប់ផ្ដើមពិនិត្យឈាម និងទឹកនោមតែម្ដង (បុគ្គលិកក្រុមហ៊ុនជ្រើសរើសពលករ អេលីត ភ្នំពេញ)។*

*ពួកយើងខ្ញុំមិនបានទទួលការផ្ដល់ប្រឹក្សាទេ (ក្រុមពលករដែលត្រលប់មកពីប្រទេសម៉ាឡេស៊ី)*

*ពួកខ្ញុំមិនត្រូវបានគេណែនាំអ្វីទេមុននឹងធ្វើតេស្តឈាមនោះ (ក្រុមពលករមុនទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ខេត្តកណ្ដាល)*

- **៣.១.១.៣ ការរក្សាការសំងាត់**

ភាពសំងាត់នៃការធ្វើតេស្តរកមេរោគអេដស៍/ជំងឺអេដស៍មានសារៈសំខាន់សំរាប់អតិថិជន ក៏ដូចជាពលករដើម្បីជៀសវាងនូវស្ថានភាពនៃការរើសអើង ដូចដែលមានចែងនៅក្នុងមាត្រាមួយចំនួន នៃច្បាប់ស្ដីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ដូចមានចែងនៅក្នុងខមាត្រាមួយចំនួនដូចខាងក្រោមៈ មាត្រា ៣៣ ចែងថា *អ្នកមានមេរោគអេដស៍/ជំងឺអេដស៍ ត្រូវទទួលបានការរក្សាភាពសម្ងាត់។ អ្នកមានអាជីពផ្នែកវេជ្ជសាស្ត្រ កម្មករ និយោជក ទីភ្នាក់ងារជ្រើសរើសបុគ្គលិកនានា ក្រុមហ៊ុនធានារ៉ាប់រង អ្នកបញ្ចូលទិន្នន័យ អ្នករក្សាសំណុំឯកសារទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ និងអ្នកដែលមានភារកិច្ចពាក់ពន្ធផ្សេងទៀត ត្រូវបានទទួលការណែនាំឱ្យយកចិត្តទុកដាក់ពីការរក្សាការសម្ងាត់ក្នុងទំនាក់ទំនងការងារ ជាពិសេសអត្តសញ្ញាណ និងស្ថានភាពផ្ទាល់ខ្លួនរបស់អ្នកមានមេរោគអេដស៍/ជំងឺអេដស៍។ និង មាត្រាទី៣៥ ចែងថា លទ្ធផលនៃការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍អាចផ្ដល់ឱ្យៈ*

*ក. ជនដែលសុំធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ដោយស្ម័គ្រចិត្ត*

*ខ. អាណាព្យាបាលស្របច្បាប់របស់អនីតិជនដែលត្រូវបានធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍*

*គ. ជនដែលត្រូវអនុញ្ញាត្តិឱ្យទទួលលទ្ធផលនេះសម្រាប់កម្មវិធីតាមដានត្រួតពិនិត្យមេរោគ អេដស៍/ជំងឺអេដស៍ ដូចមានចែងក្នុងមាត្រា៣០នៃច្បាប់នេះ និង*

*ឃ. តាមតម្រូវការរបស់តុលាការដូចមានចែងក្នុងចំណុច "គ" មាត្រា៣៤ នៃច្បាប់នេះ។*

ទោះបីជាយ៉ាងនេះក៏ដោយ ក្រុមវេជ្ជបណ្ឌិត ឬគ្រូពេទ្យដែលបានជួលដោយក្រុមហ៊ុនជ្រើសរើសពលករដើម្បីធ្វើតេស្តឈាមរកមេរោគអេដស៍ចំពោះពលករចំណាកស្រុកដែលត្រៀមទៅធ្វើការនៅក្រៅប្រទេស ខកខាននិងមិនអើរពើរក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដោយលទ្ធផលនៃការធ្វើតេស្តឈាមរបស់ពលករត្រូវបានផ្ដល់

ពតិមានមកបុគ្គលិក ឬ ភ្នាក់ងារកណ្តាលរបស់ក្រុមហ៊ុនជ្រើសរើសពលករដែលជាភាគីទីបី បានដឹងលទ្ធផលតាមរយៈទូរសព្ទ័ ដែលដំណើរការនៃការប្រាប់ពីលលទ្ធផលនេះវាផ្ទុយពីច្បាប់អេដស៏នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

*ខ្ញុំមិនអីដែរ តែប្រហែលជាអត់ទេ ព្រោះអីគាត់មិនបានជួបពេទ្យផ្ទាល់ផង គ្រាន់តែអោយក្រដាស់មកហើយ ក្រុមហ៊ុនអោយមកគាត់ (ពលករត្រៀមទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ខេត្តបាត់ដំបង)។*

- **៣.១.១.៤ យ៉េនឌ័រ និងវប្បធមិ**

ដោយយោងទៅលើច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា បានបង្ហាញថាមិនមានខមាត្រាណាមួយបានចែងទាក់ទងទៅនឹងយ៉េនឌ័រ និង វប្បធមិដើម្បីធ្វើយ៉ាងណាធានាថាអ្នកផ្តល់ប្រឹក្សាដែលវេជ្ជបណ្ឌិត ឬគ្រូពេទ្យមានក្រមសីលធមិទាក់ទៅនឹងការផ្តល់សេវារបស់ខ្លួនដល់អតិថិជននោះឡើយ។
ក្នុងន័យនេះ អ្នកផ្តល់សេវាទៅដល់អតិថិជនមិនមានគ្រប់គ្រាន់នោះទេ ផ្អែកតាមការសំភាសន៏ជាមួយស្ថាប័នពាក់ពន្ធ័ ដែលមកពីមន្ទីរពេទ្យ ក៏ដូចជាមណ្ឌលសុខភាពនៅរាជធានីភ្នំពេញ ដែលភាគច្រើននៃពួកគាត់បានបញ្ជាក់ថាមិនមានការកំនត់ពីអ្នកផ្តល់ប្រឹក្សាដែលជាបុរសត្រូវជួបនឹងអតិថិជនបុរស និងអ្នកផ្តល់ប្រឹក្សាស្រី ត្រូវជួបនឹងអតិថិជនស្រី ដើម្បីធានាពីវិសមភាពយ៉េនឌ័រក្នុងការផ្តល់សេវានោះទេ។

*អត់ទេ ជាទូទៅនៅកន្លែងយើងមានម្នាក់ជាអ្នកបូមឈាមជាមនុស្សប្រុស ប៉ុន្តែជួនកាលប្រុសហ្នឹងរវល់ទៅគឺស្រីមកជំនួសទៅយើងមិនដឹងអ្នកណាពិតប្រាកដចំពោះអ្នកពិគ្រោះយោបល់គឺស្រីទាំងអស់ (មន្ត្រីនៃមជ្ឈមណ្ឌលជំងឺសើរស្បែក និងកាមរោគ ភ្នំពេញ)។*

*ការផ្តល់ប្រឹក្សាមិនសំដៅទៅលើប្រុសរឺស្រីទេ តែសំដៅលើអ្នកដែលទុកចិត្តដោយផ្តល់ដោយមិនប្រកាន់ភេទទេ។ តែបើពិនិត្យរោគស្ត្រីវិញគឺត្រូវមានពេទ្យចូល ទៅជាមួយ១នាក់ រឺ២នាក់ ព្រោះខ្លាចមានការចោទប្រកាន់។ តេស្តអេសដ៏មិនប្រកាន់ទេ ទាំងការបូមឈាមនិង ពិនិត្យផ្តល់ប្រឹក្សាគឺធ្វើទាំង២ភេទ។ ចំពោះបញ្ហាផ្លូវភេទវិញដុកទ័រសុទ្ធតែមានជំនាញនិងបទពិសោធន៏ខ្ពស់ (មន្ត្រីនៃមន្ទីរពេទ្យព្រះកុសមៈ ភ្នំពេញ)។*

*មិនបែងចែកទេគឺចុំរះកាលមុនមានបុរស តែឥឡូវគាត់ ទៅកាន់កាល់ម៉ែត រួចគេរើសស្រីម្នាក់ទៀតប៉ុន្តែដោយ អថិតិជនថយចុះ គេដកម្នាក់ស្រីទៅកាន់ផ្នែកផ្សេងទុកតែខ្ញុំម្នាក់មិនថាបុរសរឺស្រី ខ្មើយទេ។ ប្រសិន បើអ្នកមកក្រោម១៨យើងអនុញ្ញាតិអោយមានអាណាព្យាបាលមកជាមួយ (បុគ្គលិកនៃវិទ្យាស្ថានជាតិ ប៉ាស្ទ័រ ភ្នំពេញ)។*

ទោះបីជាយ៉ាងនេះក៏ដោយ ក៏ពលករមួយចំនួនមានដែលមានបទពិសោធន៍ មុននឹងគេបញ្ជូនទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ជាអ្នកជំនួយការនៅក្នុងផ្ទះ និង ប្រទេសថៃ ក្នុងវិស័យឧស្សាហកម្មត្រូវបានគេធ្វើតេស្តរកមេរោគអេសដ៏ ថ្លើម និងប្រភេទជំងឺមួយចំនួនទៀតមានអារម្មណ៏មិនប្រក្រតីទាក់ទងនឹងបញ្ហានេះ ប៉ុន្តែមួយចំនួនទៀតមិនមានបញ្ហានោះទេ។

*.- ខ្ញុំទុកដូចជាឪព្រោះគាត់ចាស់ ។*

*- ខ្ញុំអៀនដែរ ព្រោះខ្លួនជាស្រី។*

*-ខ្ញុំអត់អៀនទេ ព្រោះគេជាពេទ្យ គេអាចមើលការខុសត្រូវលើយើងឃើញ ដូចថា គាត់ហ្នឹងប្រុស ហើយជាពេទ្យបើមិន អោយពេទ្យពិនិត្យស្មានថានឹងដឹង ហើយគាត់ជាពេទ្យប្រុសហ្នឹងខ្មាស់អី (ក្រុមពលការិនីដែលត្រលប់មកពីប្រទេសម៉ាឡេស៊ី) ។*

សេវាកម្មនៃការធ្វើតេស្តឈាមនៅក្នុងព្រះរាជាណាចក្រផ្តល់ជូនដល់ពលរដ្ឋគ្រប់រូប ប៉ុន្តែអតិថិជនដែលជាជនបរទេសត្រូវបានគេសង្កេតឃើញថាមិនសូវមកទទួលសេវានោះទេ ដែលអាចបណ្តាលមកពីឧបសគ្គមួយចំនួនដូចជា ភាសា វប្បធមិ គុណភាពនៃសេវា និង បញ្ហាមួយផ្សេងទៀត។

*អតិថិជនដែលមកទទួលសេវា នៅទីនេះមាន ៩៩ភាគរយជាជនជាតិខ្មែរនិង ១ភាគរយជាជនជាតិបរទេសយួនអឺរ៉ុប។ ពួកអឺរ៉ុបនោះភាគច្រើនមកតាមរយៈស្ត្រីជាដៃគូព្រោះពេលស្ត្រីទាំងនោះមកពិនិត្យយើងបានណែនាំពីផលប៉ះពាល់ បណ្តាលមកពីដៃគូ ដោយស្នើរអោយមានការពិនិត្យជាមួយដៃគូផងដែរ។ នៅក្នុងរយៈពេល៣ខែនេះមាន១០នាក់ជាស្ត្រីវៀតណាមដែលមកធ្វើតេស្តឈាមហើយការផ្តល់ប្រឹក្សាគឺនិយាយជាភាសាវៀតណាម (បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល មិច ភ្នំពេញ) ។*

លើសពីនេះទៀត តាមរយៈការសំភាសន៏ជាមួយពលករខ្មែរដែលត្រៀមទៅធ្វើការនៅប្រទេសម៉ាឡេស៊ី និង ថៃ បានអោយដឹងថា ពលករចំណាកស្រុកមានអារម្មណ៏ថាធម្មតាចំពោះឥរិយាបទក្នុងការទំនាក់ទំនង របស់វេជ្ជបណ្ឌិត ឬគ្រូពេទ្យ ដែលធ្វើការពិនិត្យសុខភាពដល់ពួកគេ បើទោះជាវេជ្ជបណ្ឌិត ឬគ្រូពេទ្យនោះជាបុរស ឬស្ត្រីក្តី ។

*អាកប្បកិរិយាល្អ "គាត់និយាយថាអូនដោះអាវ "(ពលការិនីត្រៀមទៅធ្វើការនៅប្រទេសថៃ) ។ពេទ្យគេរាក់ទាក់ ព្រោះស្គាល់មីង (ពលការិនីត្រៀមទៅធ្វើការនៅប្រទេសថៃ) ។អត់អីទេ ពេទ្យស្រីក៏បាន ពេទ្យប្រុសក៏បាន (ពលការិនីត្រៀមទៅធ្វើការនៅប្រទេសថៃ) ។*

- **៣.១.១.៥ ការបង្ហាញ និង ផ្តល់នូវលទ្ធផល**

យោងតាម ច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការីករាលដាល មេរោគអេដស៍/ជំងឺអេដស៍របស់ព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៣៥ បានចែងថា *លទ្ធផលនៃការធ្វើតេស្ត មេរោគអេដស៍/ជំងឺអេដស៍ អាចផ្តល់ឱ្យ:*

*ក. ជនដែលសុំធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ដោយស្ម័គ្រចិត្ត*

*ខ. អាណាព្យាបាលស្របច្បាប់របស់អនីតិជនដែលត្រូវបានធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍*

*គ.ជនដែលត្រូវអនុញ្ញាត្តិឱ្យទទួលលទ្ធផលនេះសម្រាប់កម្មវិធីតាមដានត្រួតពិនិត្យមេរោគអេដស៍/ជំងឺអេដស៍ ដូចមានចែងក្នុងមាត្រា៣០នៃច្បាប់នេះ និង*

*ឃ. តាមតម្រូវការរបស់តុលាការដូចមានចែងក្នុងចំណុច"គ"មាត្រា៣៤ នៃច្បាប់នេះ ។*

ដោយឡែក មណ្ឌលធ្វើតេស្តឈាមរកមេរោគអេដស៍ ដែលមានទំនាក់ទំនង ទៅនឹងក្រុមហ៊ុនជ្រើសរើសពលករដើម្បីបញ្ជូនទៅធ្វើការនៅក្រៅប្រទេសនោះ ជានិច្ចកាលបានប្រាប់ពីលទ្ធផលនៃការធ្វើតេស្តរបស់ពលករតាមរយៈ ភាគីទីបី ដែលជាបុគ្គលិករបស់ក្រុមហ៊ុន ឬភ្នាក់ងារកណ្តាលដែលនៅតាមសហគមន៍របស់ពួកគេ ឱ្យដឹងតាមរយៈទូរសព្ទ ឬផ្ទាល់មាត់ ។

> *គឺយើងទៅយកតែម្តង ឧបមាថាថ្ងៃនេះបាន ថ្ងៃនោះបាន យើងទៅយកហើយ ផ្ញើលទ្ធផលទៅម៉ាឡេ ដើម្បីគេរត់ការនៅទីនោះ ហើយផ្ញើរម្តងយ៉ាងតិចក៏៥-១០នាក់ឡើងទៅតែ ពិនិត្យ២ដងគឺ យើងទុកចិត្តថាអវិជ្ជមានតែម្តងជួនកាលទៅដល់ម៉ាឡេធ្វើតេស្តទៅមានរលោកថ្លើមបេ មាន៣នាក់ ហើយមាននាងមួយរលោកថ្លើមបេ ទៅដល់ម៉ាឡេបានមួយអាទិត្យ គេបញ្ជូនមកវិញខាតពេលវេលាខកចិត្តហើយក្រុមហ៊ុនខាតលុយសំបុត្រយន្តហោះទាំងទៅទាំងមក ហើយខ្ចីលុយថែមទៀត ហើយបើមានរោគស្វាយប្រម៉េះ យើងខាតបង់ ធម្មតាពេទ្យគេកុងត្រាតែ៣ខែ អញ្ចឹងគេមិនទទួលខុសត្រូវ ដល់៤ខែ នោះទេគឺយើងខាតត្រង់ហ្នឹង ។ ទាក់ទងនិងការយកតេស្តឈាម គឺគេដាក់ក្នុង ស្រោមសំបុត្រ បិទជិតគ្រាន់តែគេរាយការប្រាប់យើងពីអ្នកដែលមានមានបញ្ហា (បុគ្គលិកក្រុមហ៊ុនជ្រើសរើសពលករ អេលីត ភ្នំពេញ) ។*

> *ការទាក់ទងពិតមាន គឺតាមរយៈទូរស័ព្ទ ថាយើងមានពលករ-ពលការិនីត្រូវពិនិត្យឈាមគាត់មកពេលណាក៏បានជាទូទៅគាត់មានសហការីមកជាមួយគាត់ពីព្រោះការពិនិត្យឈាមវាមិនពិបាកទេគាត់មកដល់ភ្លាមបូមឈាមភ្លាមហើយយកទៅពិនិត្យនៅ កន្លែងគាត់ល្ងាចឡើងរឺ ថ្ងៃស្អែកគាត់តេមកប្រាប់ថាជាប់រឺធ្លាក់ពេល គាត់មកបូម ហ្នឹងក្នុងសារ៉ាំងរបស់គាត់ មានសរសេរឈ្មោះ បើយើងថាប្រញាប់ក្រោយ២-៣ម៉ោងគាត់តេមក ប្រាប់ថាជាប់ហើយយក ក្រដាស់ស្នាមមកជូនយើងវិញលទ្ធផលសំរាប់*

*ពេទ្យការងារវិញជាទូទៅយើងតែទៅ ប្រាប់គាត់ថាមានពលករ មួយក្រុមដែលត្រូវយកទៅពិនិត្យ ពេលគាត់បានដឹងគាត់នឹងរៀបចំ ពេលណាពិនិត្យ ខាងយើងអីអញ្ជើងទៅពេទ្យ ការងារក៏ គេពិនិត្យ ជាទូទៅដែរដូចជាកម្មករសហគ្រាស រោងចក្រក្នុង ស្រុកខ្មែរយើង លទ្ធផលអ្វីគ្រប់យ៉ាងគឺ យើងទៅយកខ្លួនឯង គាត់មិនអាចបញ្ជូនមកអោយយើងបានទេក៏មិនអាច តេ មកប្រាប់យើងបាន ដែរគឺយើងជាអ្នកតាមដានខ្លួនឯងនេះ គឺសំរាប់ពេទ្យការងារលើកលែងពេទ្យឯកជនសេវាកម្មលឿនក៏ ដូចជាសំរួលដល់ពលករ-ពលការិនីបានដឹងលទ្ធផលគាត់លឿន ( បុគ្គលិកក្រុមហ៊ុន ហ្វីលីម័រ ភ្នំពេញ) ។*

ការផ្តល់ និង បង្ហាញពីលទ្ធផលនៃការធ្វើតេស្តឈាម រកមេរោគអេដស៏របស់ពលករភាគច្រើនត្រូវបានគេធ្វើឡើងតាមរយៈក្រុមហ៊ុន ឬបុគ្គលិករបស់ក្រុមហ៊ុនព្រោះថាវេជ្ជបណ្ឌិត ឬគ្រូពេទ្យដែលបានជួលដោយក្រុមហ៊ុនបានបូមយកឈាមរបស់ពលករខណៈដែលពួកគេស្នាក់នៅមណ្ឌលបណ្តុះបណ្តាលរបស់ក្រុមហ៊ុន។

*រយះពេល១ថ្ងៃ បានទទួលលទ្ធផល ។ ខ្ញុំដឹងតាមរយះគ្រូ ព្រោះពេទ្យគេប្រាប់គ្រូហើយគ្រូប្រាប់យើង ។ ប្រហែលជា ២នាទី ចំណាយក្នុងការបូមឈាម ។ កាលខ្ញុំទៅពិនិត្យមានគ្នា ២ ទៅ ៣ នាក់ ហើយគ្មាននរណាប្រាប់ពីការបូមឈាមទេ គេគ្រាន់តែជួសហើយគេយកទៅពិនិត្យ ។ គ្រូមិនបាននិយាយ អីទេ គ្រាន់តែប្រាប់ថាជាប់ហើយ អាចនៅក្នុងមណ្ឌលនេះបាន ចំពោះអ្នកធ្លាក់ក្រុមហ៊ុនអោយត្រលប់ទៅផ្ទះវិញ ក្រុមហ៊ុនជូនទៅ ។ អ្នកដែលធ្លាក់ជួនកាល រោគថ្លើម ហើយនិងអេដស៏ ចំពោះអ្នកធ្លាក់គេមិនអោយនៅយូរទេខ្លាចឆ្លងដល់អ្នកផ្សេង( ពលការិនីត្រលប់មកពីប្រទេសម៉ាឡេស៊ី) ។*

- **៣.១.១.៦ ការធ្វើតេស្តបញ្ជាក់បន្ថែមពីលទ្ធផល**

ការធ្វើតេស្តបញ្ជាក់បន្ថែមពីលទ្ធផលកំរ នឹងធ្វើឡើងដោយស្ថាប័នជំនាញនៅក្នុងព្រះរាជាណាចក្រកម្ពុជាណាស់ពីព្រោះថាលទ្ធផលដែលចេញដោយស្ថាប័នត្រូវបានទទួលស្គាល់ជាសាធារណៈ។ នេះបើតាមការអះអាងរបស់មន្ត្រីពាក់ពន្ធ័ដែលបានផ្តល់ការសំភាសន៏បានបញ្ជាក់ថា ភាគច្រើននៃលទ្ធផលធ្វើតេស្តឈាមរកមេរោគអេដស៏ដែលមិនច្បាស់ នឹង ត្រូវគេធ្វើតេស្តសារជាថ្មីពីរដងទៀត ដើម្បីធានាថាលទ្ធផលនោះអាចទទួលយកបានមុនផ្តល់ដល់អតិថិជន ក៏ដូចជាពលករ។

*តេស្តឈាមត្រូវ ធ្វើ២ទៅ៣ដងទើប លទ្ធផលដឹងច្បាស់ ។ហើយតំលៃនៃការធ្វើតេសឈាមគឺៈបើតាមរយះការធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត គឺមិនយកថ្លៃសេវាទេតែលទ្ធផលមិនអាចយកទៅប្រើការជាសាធារណៈបាន ពីព្រោះមិនដាក់ឈ្មោះអ្នកជំងឺទេមានតែលេខកូដតែបើធ្វើតាមរយៈមន្ទីពេទ្យត្រូវបង់ថ្លៃសេវានិងលទ្ធផលអាចប្រើប្រាស់ជាសាធារណៈបាន។*

*វិធីវិភាគ :*

*- PA ( Serodia)*
*- Determin HIV/ Uni- Gold*

*-Western Blood : ធ្វើដើម្បីបញ្ជាក់ករណីលទ្ធផលវិភាគវិជ្ជមាន*

*ក្នុងករណីនេះអ្នកជំងឺត្រូវបង់ថ្លៃសេវានេះ បន្ថែម រឺ ផ្តល់យោបល់អោយអ្នកជំងឺទៅពិនិត្យដោយខ្លួន ។*

*តំលៃវិភាគ :*

*- Serodia or Dertermine/ Uni- Gold : 10000R*

*- Western Blood : 30 USD ( មន្ត្រីនៃមន្ទីរពេទ្យព្រះកុសមៈភ្នំពេញ)*

- **៣.១.១.៧ ការគ្រប់គ្រងមណ្ឌលផ្តល់ប្រឹក្សា**

យោងមាត្រា ៣១ នៃច្បាប់ស្តីពីការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៏/ជំងឺអេដស៏ ចែងថា *គ្រប់កន្លែងធ្វើតេស្តមេរោគអេដស៏/ជំងឺអេដស៏ (HIV/AIDS) ត្រូវកំណត់យកវិធានការក្នុងការធានា ចំពោះការរក្សាភាពសម្ងាត់នៃរបាយការណ៏ កំណត់ត្រាវេជ្ជសាស្ត្រ ពត៌មានផ្ទាល់ខ្លួន រួមបញ្ចូលទាំងពត៌មានទាំងអស់ដែលអាចទទួលបានពីប្រភពពត៌មានផ្សេងៗ ក្នុងការអនុវត្តន៏កម្មវិធីតាមដានត្រួតពិនិត្យ ។ កម្មវិធីតាមដានត្រួតពិនិត្យនេះត្រូវប្រើប្រាស់នូវប្រពន្ធ័កូដ ដើម្បីធានាអោយមានភាពអនាមិក។* បើតាមការអះអាងរបស់មន្ត្រីមកពីស្ថាប័នពាក់ពន្ធ័បានផ្តល់ការសំភាសន៏បញ្ជាក់ថា គោលការណ៏នេះ ត្រូវបានអនុវត្តន៏ដោយមណ្ឌលផ្តល់ប្រឹក្សាទាំងអស់ ដែលបុគ្គលិកធ្វើការនៅក្នុងមណ្ឌលទាំងនេះត្រូវបានទទួលនូវការបណ្តុះបណ្តាលដើម្បីធានាពីប្រសិទ្ធិភាពការងារនិងការត្រួតពិនិត្យផងដែរ ។

*ចំពោះការត្រួតពិនិត្យទៅលើស្តង់ដារ ទាំងនោះគឺយើងតាមរយៈផ្ទៃក្នុងដោយមានការប្រជុំរយៈពេល៣ខែម្តង ហើយទទួលការវាយតំលៃពី NCHADS រយៈពេល២ឆ្នាំតែម្តង ( បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល មិច ភ្នំពេញ) ។*

- **៣.១.១.៨ ផលប៉ះពាល់នៃលទ្ធផល**

យោងមាត្រាទី៣៩ នៃច្បាប់ស្តីពីការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៏/ជំងឺអេដស៏ ចែងថា *ហាមដាច់ខាតការរើសអើងចំពោះអ្នកមានមេរោគអេដស៏/ជំងឺអេដស៏ ក្នុងការទទួលតំណែងសាធារណៈ ។ សិទ្ធិក្នុងការស្វែងរកតំណែងសាធារណៈដោយការបោះឆ្នោត ឬការចាត់តាំងតម្លើងឋានៈ មិនត្រូវបដិសេធចំពោះជនណាម្នាក់ ដោយសារតែការដឹង ឬសង្ស័យថាជននោះ ឬក្រុមគ្រួសាររបស់ជននោះមានមេរោគអេដស៏/ជំងឺអេដស៏ ។*

គោលការណ៏ស្នូរគ្រ័នៃការធ្វើតេស្តរកមេរោគអេដស៏មានចែងនៅក្នុងច្បាប់ ស្តីពីការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៏/ជំងឺអេដស៏ និងត្រូវបានគេផ្សព្វផ្សាយជាសាធារណៈដល់ប្រជាពលរដ្ឋតាមប្រពន្ធ័

ពតិមានដោយធ្វើយ៉ាងណាអោយអត្រាមេរោគអេដស៍/ជំងឺអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានការថយចុះ។ ដោយឡែក ការធ្វើតេស្តរកមេរោគអេដស៍/ជំងឺអេដស៍បានតំរូវដោយប្រទេសទទួល និងមានការទទួលខុសត្រូវដោយក្រុមហ៊ុនជ្រើសរើសពលករ និងធ្វើឡើងដោយនាយកដ្ឋានពេទ្យការងារ ក៏ដូចជាគ្លីនិចឯកជន និងស្ថាប័នដែលពាក់ពន្ធ័មុននឹងបញ្ជូនទៅមណ្ឌលបណ្តុះបណ្តាលរបស់ក្រុមហ៊ុននិងរង់ចាំការធ្វើដំណើរទៅប្រទេសសទទួល។ ក្នុងន័យនេះ បើតាមការអះអាងរបស់ក្រុមហ៊ុនជ្រើសរើសពលករនៅភ្នំពេញបានអោយដឹងថា វាអាចជះឥទ្ធិពលដល់ក្រុមហ៊ុន ក្នុងករណីដែលត្រូវបានរកឃើញថា លទ្ធផលនៃការធ្វើតេស្តរកមេរោគអេដស៍/ជំងឺអេដស៍វិជ្ជមាន និងធ្លាក់តេស្តដោយសារតែមិនបំពេញនូវតំរូវការរបស់ក្រុមហ៊ុននោះ នឹងនាំអោយខាតបង់ថវិការរបស់ក្រុមហ៊ុនដែលបានចំណាយចំពោះពលករលើថ្លៃធ្វើដំណើរ ពិនិត្យសុខភាព និងពេលវេលាក្នុងការបញ្ជូនពួកគេទៅសហគមន៍របស់គេ។

*បើលទ្ធផលវិជ្ជមានគឺមិនព្រមទទួលទេយើងបញ្ជូនទៅផ្ទះបើអត់លុយគឺចេញលុយអោយតែបើមានលុយគឺទៅ ខ្លួនឯងគ្រាន់តែយើងតេប្រាប់ទៅម្តាយថា កូនធ្លាក់សំភាសន៍។ ចំពោះខ្លួនគាត់ផ្ទាល់មាន ផលវិបាកអស់សង្ឃឹម តូចចិត្ត ចំណែកផលវិបាកក្រុមហ៊ុនសោកស្តាយ យើងខំបង្រៀនគាត់ និងការ ចំណាយលុយទៅគាត់អស់ច្រើន ដល់គាត់អត់បានជោគជ័យយើងមានតែសោកស្តាយ។ កន្លែងខ្ញុំមិនដូច គេទេមកចុះឈ្មោះហើយការយកលុយមិនដូចគេទេ បើខាងម៉ាឡេគេទាមទារ ខ្ញុំថាខ្មែរក្រណាស់គេ ក៏ព្រមតាមខ្លះអោយខ្ចីលុយ១៣០ដុល្លា ទៅដល់ម៉ាឡេវត់បាត់ ក្រុមហ៊ុនខាត គេបានទាក់ទង មកខាងខ្ញុំអោយទៅយក១៣០ដុល្លាពីពលការនីមកវិញ តែមាននរណាគេអោយបើគេយកហើយ។ គេធ្វើបាបពួកខ្ញុំច្រើនផលវិបាកយើងគឺចំណាយលើគេ តែចំពោះតំលៃគឺថេរ អត់មានឡើងវិចុះទេគឺ ២៥-៣០ដុល្លា តាមពិតពេលខ្ញុំធ្វើដំបូងនៅពេទ្យការងារ៥០ដុល្លា ពេលខ្ញុំទៅចរចានៅពេទ្យរូស្ស៊ី គេថា២៥ដុល្លាខ្ញុំថាបូកអោយអស់គេថា៣០ដុល្លា អញ្ចឹងខ្ញុំអោយ៣០ដុល្លា។ យើងធ្វើការជាមួយ បរទេសយើងដឹងស្រាប់ហើយឧបមាថា ២៥ដុល្លាហើយសុំថែម៥ដុល្លាទៀត។បើអញ្ចឹងខ្ញុំប្រាប់ថាដាក់ តំលៃអោយខ្ពស់អោយហើយមក ជួនកាលម៉ាឡេគេយល់ច្រឡំថាយើងយកលុយកុំមីស្យុង។ គាត់ថា ៣០ដុល្លា ខ្ញុំក៏ធ្វើអស់មួយរយៈ គាត់ទារអោយគេដឹង គឺ អ្នកស្រីមេឌិនដឹង ក៏ទៅជួបជាមួយលោក វេជ្ជបណ្ឌិត។ វេជ្ជបណ្ឌិតគាត់យក៣៥ដុល្លា គេអោយខ្ញុំ៣០ដុល្លា ពេទ្យឡើងថ្លៃ៥ដុល្លាខ្ញុំបង់៣៥ដុល្លា គាត់ធ្វើបាបពួកខ្ញុំអញ្ចឹងអ្នកខ្លះគេធ្វើតែ២០ដុល្លាផង ធ្វើកន្លែងណាស្រួល ធ្វើតែកន្លែងហ្នឹងទៅ ខាងក្រុមហ៊ុនម៉ាឡេ គេផ្ញើលុយមកពលករមិនដែលចំណាយទេគេជួយសព្វបែបយ៉ាង គឺជួយអ្នកក្រីក្រ ដូចជា ថ្នាំសង្កូវ ថ្នាំដុសធ្មេញវិក័យប័ត្រមួយខែៗពី២០០-៣០០ដុល្លា គឺឈឺក្បាលតែម្តង នៅថ្លៃពេទ្យប្រចាំមណ្ឌលក្នុងមួយខែៗពី ២៥០-៣០០ដុល្លាដែរគឺ ព្យាបាលចុកពោះ រោគស្ត្រី អស់៥០-៦០ដុល្លាម្តងៗ ហើយខ្លះក៏រត់ទៅបាត់ទៅ។ ខាំរាមគួរ ព្យាយាមរកពេទ្យអង្គការណាដែលមិនគិតថ្លៃថ្នាំ ថែមទៀត។ ចំពោះពលករ*

*ម្នាក់៧គឺធ្វើតេស្ត២ដងហើយពេលទៅដល់ម៉ាឡេគេពិនិត្យទូទៅម្តងទៀតក្រុមហ៊ុនចំណាយទៀតគេទូទាត់គឺកាត់៤ខែគេកាត់ក្នុងនោះតែម្តង (បុគ្គលិកក្រុមហ៊ុនជ្រើសរើសពលករ អេលីត ភ្នំពេញ) ។*

*មាន២ដំណាក់កាល ដំណាក់កាល ទី១ ពិនិត្យឈាម ដំបូងឃើញថាមានបញ្ហាពាក់ពន្ធ័ជា មួយឈាម ឧទាហរណ៏ថា លទ្ធផលឈាមមានជំងឺឆ្លងគឺយើងទុកឱកាសអោយគាត់ទៅព្យាបាលយើងអាចផ្តល់ថវិកាអោយគាត់៧ក៏បានគាត់ដោះស្រាយខ្លួនគាត់ ក៏ប៉ុន្តែយើងមិនអនុញ្ញាត អោយគាត់ស្នាក់នៅព្យាបាល នៅទីនេះទេ វាអាចឆ្លងក៏ដូចជាជំងឺថ្លើមដែរវាមាន២ប្រភេទព្យាបាលជានិងព្យាបាលមិនជាអាហ្នឹងក៏អាស្រ័យលើសាម៉ីខ្លួនដូចគ្នា ក៏ប៉ុន្តែផលវិបាករបស់ពួកគាត់ ជាទូទៅភាគច្រើនគឺបញ្ហាថ្លើម អេដស៏អីហ្នឹង គឺយើងមិនបានធ្វើការសហការណ៏ខាងបណ្តាញអង្គការ បណ្តាពេទ្យរដ្ឋនៅពេលគឺដែលយើងដឹងថាលទ្ធផល*

*គាត់ធ្លាក់ហើយយើងគួរធ្វើរបាយការណ៏អោយខាងពេទ្យ ដែលពាក់ពន្ធ័អោយបានដឹងយើងមិនដែលធ្វើចំពោះបញ្ហានេះក៏ប៉ុន្តែយើងណែនាំគាត់បងស្រីបងប្រុសមានបញ្ហាជាទូទៅដូចជាបញ្ហាជំងឺអេដស៏យើងមិនសូវហ៊ានប្រាប់គាត់ប្រាប់ទៅអ្នកដែលនាំគាត់មករឺគ្រួសារ អោយគាត់រកវិធី ពន្យល់ខ្លួនគាត់ជៀសវាងគាត់គិតខ្លី ។ ផលវិបាក ខាងក្រុមហ៊ុនជាធម្មតាប៉ះពាល់ច្រើនណាស់ទី១ថ្លៃធ្វើដំណើរមកទី២ គឺថ្លៃពេទ្យគេមិនដឹងជាប៉ើរឺក៏ធ្លាក់ទេគេដឹងតែពិនិត្យហើយគឺដឹងថាបង់ថ្លៃពេទ្យអោយគេនេះជាផលវិបាកក៏ដូចជាការប៉ះទង្គិចមួយដែរលទ្ធផលនៃការជ្រើសរើសជួនកាលគាត់ធ្លាក់អញ្ចើងទៅ ខ្មែរយើងតែងតែមានអារម្មណ៏មួយថាច្រណែននៅពេលដែលគាត់មិនបានអី គេបានទៅ គាត់ធ្វើអោយអ្នកផ្សេងមិនបានដូចគាត់ដែរ ជួនកាលគាត់និយាយអីអោយប៉ះទង្គិច តែមួយចំនួនទេ នេះក៏ជាផលវិបាកមួយដែរ (បុគ្គលិកក្រុមហ៊ុនជ្រើសរើសពលករ ហ្វីលីម័រ ភ្នំពេញ) ។*

ទោះបីជាយ៉ាងណាក៏ដោយ បើតាមការអះអាងរបស់ពលករដែលមាន បទពិសោធន៏ក្នុងការធ្វើតេស្តរកមេរោគអេដស៏/ជំងឺអេដស៏ និង ថ្លើមមុនពេលទៅធ្វើការក្រៅប្រទេសបញ្ជាក់ថាពួកគេត្រូវបានរើសអើងពីសង្គមក៏ដូចជា អ្នកជិតខាងរបស់ពួកគេផងដែរទាក់ទងទៅនឹងការផ្ទុកមេរោគអេដស៏/ជំងឺអេដស៏ ដែលពលករមួយចំនួនត្រូវបានគេដាក់អោយនៅដាច់ដោយឡែកទាំងការហូបចុក និងស្នាក់នៅខណៈដែលពួកគេមានផ្ទុកមេរោគអេដស៏/ជំងឺអេស៏ ឬ ក៏មេរោគថ្លើម ។ លើសពីនេះទៅទៀត គឺពួកគេអាចនឹងមានវិប្បដិសារីដែលគោលបំណងរបស់ពួកគេទៅធ្វើការនៅក្រៅប្រទេសរបស់ពួកគេដើម្បីបានថវិការមកផ្គត់ផ្គង់គ្រួសារត្រូវបានបញ្ចប់ និង ត្រូវបានក្រុមហ៊ុនបញ្ជូនមកសហគមន៏របស់ពួកគេវិញ ។

*ខ្ញុំនៅកំលោះ ចំពោះឪពុកម្ដាយពេលយើងអត់បានទៅស្រុកគេគឺពិបាកដែរ ព្រោះយើងរៀនបានក៏តែទាប មិនដឹងធ្វើអីកើត អ្នកជិតខាងគេសើច យំ គេថាយើងមិនចេះប្រមាថខ្លួន។ របស់គេហាមមិនអោយយើងទៅបំពាន បើមានរោគថ្លើមអាហ្នឹងយើងមិនដឹងទេ តែបើអេដស៍គេស្អប់តែម្ដង (ពលករបុរសដែលត្រលប់មកពីប្រទេសថៃ)។*

- **៣.១.១.៩ ការទទួលសេវាព្យាបាល ថែទាំ និង គាំទ្រដល់ពលករ**

មាត្រាទី២៦នៃច្បាប់ ស្ដីពីការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ចែងថា *រដ្ឋត្រូវធានាឱ្យអ្នកមានមេរោគអេដស៍/ជំងឺអេដស៍ ទទួលបាននូវសេវាថែទាំសុខភាពបឋម ដោយឥតបង់ថ្លៃ តាមបណ្ដាញសុខភាពទាំងអស់របស់រដ្ឋ និងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន។* និងមាត្រាទី២៧ ចែងថា *រដ្ឋត្រូវចលនាពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋគ្រួសារ អង្គការនានា ព្រះសង្ឃ ក្រុមបព្វជិតសាសនា និង ក្រុមអ្នកដែលប្រឈមនឹងគ្រោះថ្នាក់បំផុត សំដៅឧបត្ថម្ភ ថែទាំ និង ព្យាបាលអ្នកមានមេរោគអេដស៍/ជំងឺអេដស៍នៅគ្រប់លំដាប់ថ្នាក់ទូទាំងព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះដែរមាត្រាទី ២៩ចែងថា រដ្ឋត្រូវយកចិត្តទុកដាក់បន្តជំរុញការបង្ការ និងគ្រប់គ្រងជំងឺកាមរោគ ក្នុងគោលដៅជួយទប់ស្កាត់ការ ឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍។*

*សំរាប់អ្នកលទ្ធផលវិជ្ជមាន ចំពោះម៉ិចក៏មានផលវិបាកត្រង់ ត្រូវពន្យល់អោយបានច្រើន ពេលខ្លះគាត់ចង់ស្លាប់ពេលបានដឹងលទ្ធផល ហើយអ្នកខ្លះណែនាំសេវាអោយទៅ ហើយតែគាត់មិនទៅទៀត ហើយសំរាប់អ្នកវិជ្ជមាន វិញគឺមានផលប៉ះពាល់ពីក្រុមគ្រួសារ សង្គម ការងារ ហើយមានការយ៉ាប់យឺនផ្លូវចិត្ត។ ហើយចំពោះអ្នកខេត្តវិញកាន់ តែលំបាកដោយមិនទាន់មានសេវា ព្យាបាលណាទៅដល់ ដូចនេះហើយក៏វាមានការទាក់ទងនិង ការមិនចង់ធ្វើតេស្តឈាម (បុគ្គលិកអង្គការមិច ភ្នំពេញ)។*

*គោលការណ៍ ទៅអនាគត អង្គការ រ៉ាក់ និង ពង្រីកទៀតដើម្បីបំពេញតំរូវការរបស់អតិថិជន។ប៉ុន្តែបើសិនបើតាមខ្ញុំគិតប្រហែលថា គ្រប់គ្រាន់ហើយ តែនៅខ្វះ តែការផ្ដល់ARV ទេដោយខាងយើងបើជួបអ្នកមានផ្ទុក គឺយើងបញ្ជូនទៅកន្លែងផ្សេង។ យើងមានសេវាមួយទៀត គឺសេវាថែទាំ ក្រោយការ រលូតកូនដូចគាត់ មានការធ្លាក់ឈាម យកចេញមិនអស់ គឺយើងជួយសំអាតខ្លួនអោយគាត់ តែមិនមែនសេវារំលូតកូនចេញនោះទេ (បុគ្គលិកអង្គការរ៉ាក់ ភ្នំពេញ)។*

ក្នុងនោះដែរ ដោយយោងទៅទៅតាមការឆ្លើយរបស់ពលករដែលបានអ្នកចូលរួមសំភាសន៍ឱ្យដឹងថាពួកគេត្រូវការការគាំទ្រពីក្រុមគ្រួសាររបស់គេប្រសិនបើលទ្ធផលនៃការធ្វើតេស្តបញ្ជាក់ថាមានផ្ទុកមេរោគអេដស៍ និង

ជំងឺផ្សេងទៀត និងម្យ៉ាងវិញទៀត ពួកគេចូលចិត្តស្វែងរកនូវសេវាសុខភាពឯកជនជាជាងសេវាសុខភាព ដែលកំពុងមាននៅក្នុងសហគមន៍របស់ពួកគេ ។

- **៣.១.១.១០ ចំនួនដងនៃការធ្វើតេស្ត**

ការពិនិត្យសុខភាព ជានិច្ចកាលត្រូវបានធ្វើទៅលើពលករដែលត្រៀមខ្លួនទៅធ្វើការនៅប្រទេសថៃ ម៉ាឡេស៊ី និង សាធារណៈកូរ៉េ ដែលជាតំរូវការរបស់ប្រទេសទទួលនឹងបានធ្វើឡើងដោយនាយកដ្ឋានពេទ្យការងារ ដែលពួកគេភាគច្រើនបានដឹងតាមរយៈក្រុមហ៊ុននៅពេលប្រកាសជ្រើស ថាការធ្វើពិនិត្យសុខភាពនឹងត្រូវគេធ្វើឡើងជារៀងរាល់ឆ្នាំសំរាប់ប្រទេសម៉ាឡេស៊ី ។

*ខ្ញុំបានធ្វើតេស្តចំនួន២ដង ដែលលើកទី១នៅពេលដែលខ្ញុំទៅដល់ប្រទេសគេ និងធ្វើប្រចាំឆ្នាំម្តងទៀត ( ពលការិនីត្រលប់ពីប្រទេសម៉ាឡេស៊ី) ។*

*ពួកយើងត្រូវគេពិនិត្យសុខភាពប្រចាំឆ្នាំ ( ពលការិនីត្រលប់មកពីប្រទេសម៉ាឡេស៊ី ខេត្តកំពង់ធំ) ។*

*ពួកយើងត្រូវគេតេស្តម្តងទៀតនៅម៉ាឡេស៊ី និងអាចតេស្តនៅពេលស្នាក់នៅផ្ទះថៅកែ ( ពលការិនីត្រលប់មកពីប្រទេសម៉ាឡេស៊ី) ។*

- **៣.១.១.១១ តំលាភាព និង ភាពច្បាស់លាស់នៃពត៌មានការធ្វើតេស្ត**

ដំណើរការនៃការជ្រើសរើសពលករត្រូវបានគេផ្សព្វផ្សាយតាមប្រពន្ធ័ពត៌មានក្នុងស្រុកដូចជា កាសែត វិទ្យុ និង ទូរទស្សន៍ សំរាប់ប្រជាពលរដ្ឋដែលចាប់អារម្មណ៏ និងមានបំណងទៅធ្វើការនៅក្រៅប្រទេសដែលក្នុងនោះក្រុមហ៊ុនជ្រើសរើសពលករបានបង្កើតនូវការិយាល័យសាខា នៅតាមបណ្តារខេត្តមួយចំនួនក្នុងគោលបំណងដើម្បីទាក់ទាញអតិថិជនបន្ថែមទៀត ។

តាមរយៈការសំភាសន៏ជាមួយពលករដែលត្រៀមខ្លួនទៅធ្វើការនៅប្រទេសថៃ និង ម៉ាឡេស៊ីបានឱ្យដឹងថា ពួកគេបានដឹងជាមុនពីពត៌មាននៃការពិនិត្យសុខភាព ធ្វើតេស្តរកមេរោគអេដស៏/ជំងឺអេដស៏ កាមរោគ រោគថ្លើម ទឹកនោម រោគទឹកនោមផ្អែម ពិនិត្យប្រូតេអ៊ីននៅក្នុងទឹកនោម របេង ប្រមេះ មហារីក និង ប្រភេទជំងឺមួយចំនួនទៀត តាមរយៈវិទ្យុ កាសែត ទូរទស្សន៍ ភ្នាក់ងារជ្រើសរើស និង បុគ្គលិករបស់ក្រុមហ៊ុន មុនពេលដែលពួកគេសំរេចចិត្តទៅធ្វើការ ។ ក្នុងន័យនេះពួកគេបានដឹងពីពត៌មាននៃការការតេស្តជាមុនតាមរយៈ អ្នកជិតខាង បងប្អូន និង ពលករដែលត្រលប់មកពីក្រៅប្រទេស ។

*មុនមកយើងបានដឹងហើយថា មានការពិនិត្យសុខភាព បូមឈាមរួចចូលរៀនទៅក្នុងមណ្ឌល ហើយក៏បានដឹងតាមរយៈការផ្សាយតាមវិទ្យុ រួចក្រុមហ៊ុនប្រាប់ផ្ទាល់មាត់ទៀត ចូលមកក្រុមហ៊ុនបាន១ថ្ងៃ ជួសឈាមតែម្តងនៅក្នុងមណ្ឌល ពេទ្យប្រចាំតែម្តង ។ ពេទ្យគេយកឈាមទៅក្រៅ រយះពេល២ថ្ងៃទើបបានលទ្ធផល ក្រុមហ៊ុនជាអ្នកប្រាប់ (ពលករិនីត្រលប់ពីម៉ាឡេស៊ី) ។*

- **៣.១.១.១២ ឧបករណ៏នៃការធ្វើតេស្ត**

មានបទដ្ឋាននៃឧបករណ៏សំរាប់មណ្ឌលផ្តល់ប្រឹក្សា រក្សាការងារសម្ងាត់ និងធ្វើតេស្តដោយស្ម័គ្រចិត្ត ដែលបានបង្កើតដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺកាមរោគ និង មេរោគអេដស៏/ជំងឺអេដស៏ គឺដើម្បីធានាពីគុណភាព និង ប្រសិទ្ធភាពនៃការបង្កើតមណ្ឌលនេះ។ បើយោងទៅតាមគោលការណ៏ស្តីពីការបង្កើតមណ្ឌលផ្តល់ប្រឹក្សា រក្សាការងារសម្ងាត់ និងធ្វើតេស្តដោយស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺកាមរោគ និង មេរោគអេដស៏/ជំងឺអេដស៏ ឆ្នាំ ២០០៤។ ដែលឧបករណ៏មានរាយនាមដូចខាងក្រោមនៅក្នុងមណ្ឌលៈ

១. គ្រឿងសង្ហារឹមៈ
   - គ្រែ១ សំរាប់ការបូមឈាម
   - តុ១ សំរាប់ការបូមឈាម
   - តុ ការិយាល័យ ២
   - កៅអីសំរាប់ការិយាល័យចំនួន ៦
   - កៅអីទទួលភ្ញៀវចំនួន ២
   - ក្តារខៀនចំនួន ២
   - កៅអីសំរាប់ពិសោធន៏ចំនួន ២

២. ឧបករណ៏នៅក្នុងការិយាល័យ
   - កុំព្យូទ័រមួយកំប្លេរ
   - UPS ចំនួនមួយ
   - ម៉ាស៊ីនព្រីនធរ (ឡាស៊ែរ) ចំនួន១
   - ម៉ាស៊ីនព្រីនធរ (កាទ្រិក) ចំនួន១
   - អូតូវ៉ុលមួយ
   - ឪសស្តេត ៤
   - ម៉ាស៊ីនត្រជាក់ ២

- ទូរទឹកកកមួយ
- កង្ហារ ២

៣. ឧបករណ៍នៅមន្ទីរពិសោធន៍

- Pipettes (Micropipettes) 20 – 200ul ចំនួន ១
- Pipettes 20 -1000ul ចំនួន ១
- “U” shapped micro plates ចំនួន ១២
- Centrifuge ចំនួន ១
- Plate shakers ចំនួន ១

ដោយឡែក គោលការណ៍នេះត្រូវបានអនុវត្តន៍ដោយមណ្ឌលសុខភាពសាធារណៈ ក៏ដូចគ្លីនិចរបស់អង្គការដែលទទួលការអនុញ្ញាត្តិពីក្រសួងសុខាភិបាលផងដែរ។ បើតាមការសំភាសន៍ជាមួយគ្លីនិចឯកជននៅភ្នំពេញបានឱ្យដឹងថា គ្លីនិចឯកជនដែលបំរើសេវានេះមិនអាចអនុវត្តន៍បានទំាងស្រុងទៅតាមគោលការណ៍នេះទេ ក៏ព្រោះត្រូវចំណាយថវិការច្រើនទៅលើឧបករណ៍ និងសំភារៈ ប៉ុន្តែសំរាប់ឧបករណ៍នៅក្នុងមន្ទីរពិសោធន៍របស់ពួកគេមានលក្ខណៈទំនើបផងដែរ ដោយបាននាំចូលមកពីបរទេស។

*ម៉ាស៊ីនខ្ញុំយកមកពីបារាំង ខ្ញុំទិញពីអ៊ឺរ៉ុបក្នុងទីណង់តាល់ ម៉ាស៊ិនខ្ញុំទំនើបស្រាប់ហើយ មានតែបូររាងរបស់ខ្ញុំធន់ កណ្ដាល មានតែដូរអាធំតែអាធំក៏អត់មានអីមើលដែរ បើអានោះប្រើមិនដែលអស់ផង។ ខ្ញុំទំនាក់ទំនង ក្រុមហ៊ុនច្រើនអញ្ចឹង គាត់ផ្ដល់អោយខ្ញុំថាពេទ្យចន្ទ្រាល្អណាស់ ព្រោះលឺល្បីមែនទែនខ្ញុំសូមសរសើរ? ឧបករណ៍ទំនើប ហើយសេវាថោក អ្នកណាមួយមិនចង់រកសេវាល្អ ខ្ញុំយល់ថាយើងមិនអាចទៅទាមទារធំៗបានទេ ហើយតំបន់នេះជាតំបន់រោងចក្រ ហើយជាតំបន់កសិកម្ម ហើយជាពិសេសកម្មករដែលយើងទទួលជាអ្នកក្ររកនូវការដែលយើងត្រូវ Collect លុយគេនោះ ហើយបើយើងក្រឡេកមើលទៅឃើញថាប្រាក់ចំណូលគេគឺតិចៗបំផុត បើសិនយើងធ្វើអាត្រាតំលៃហ្នឹងខ្ពស់ ចង់និយាយថាអោយប្រហាក់ប្រហែលនឹងគេខាងក្នុងតំបន់នេះ ដឹងថាគ្មានរត់មិនរួចទេ ដល់ទៅមិនរួចគាត់ ប្រមើលស្រមៃទៅតាមពេទ្យដែលនៅជិតផ្ទះ អញ្ចឹងយើងត្រូវការបន្ទាប និងកាត់បន្ថយភាពចំណេញ ឧទាហរណ៍ថា ១00អញ្ចឹងអោយចំណេញ៥0 -៦0 ប៉ុណ្ណោះ កាត់កងទៅអោយបុគ្គលិកយើងអស់ ៤0-៥0អីទៅនៅសល់តែ៤-១0 រៀលអីទៅបានហើយ មិនចំណេញច្រើនដូចគេៗចំណេញ១0រៀល យើងចំណេញតែ៧*

*ឥវៀលអញ្ចឹងទៅ យើងបន្ទាបអោយទាបអញ្ចឹងទៅបានយើង អាចអោយបុគ្គលិករោងចក្រមកបាន (បុគ្គលិកគ្លីនិចចន្ទ្រា ភ្នំពេញ ។*

លើសពីនេះ ពលករយល់ថាមណ្ឌលធ្វើតេស្តដែលគ្រប់គ្រងដោយរដ្ឋ និង គ្លីនិចឯកជនមានឧបករណ៍ និងអនាម័យ ល្អព្រោះថាពួកគេមិនដែលប្រទះនូវឧបករណ៍ទាំងនោះ ។ ភាគច្រើននៃពួកគេត្រូវបញ្ជូនទៅធ្វើតេស្ត ឈាមដោយក្រុមហ៊ុនជ្រើសរើសពលករមុននឹងត្រូវបញ្ជូនទៅធ្វើការនៅក្រៅប្រទេស ។

*វាមានការខុសប្លែកពីប្រទេសយើងត្រង់ឧបករណ៍និងម៉ាស៊ីនទំនើបជាងយើង(ពលករត្រលប់ពីប្រទេសថៃ ខេត្តកំពង់ធំ)*

*វាទំនើបណាស់ ក៏ដោយសារខ្ញុំមិនឃើញវាដែរ (ពលការិនីត្រលប់មកពីម៉ាឡេស៊ី ខេត្តកំពង់ធំ)*

- **៣.១.១.១៣ ទិដ្ឋភាព និង តំលៃនៃការធ្វើតេស្ត**

ថ្លៃព្យាបាល និង ការធ្វើតេស្តរករោគអេសដ៏/ជំងឺអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនមានកំណត់ ជាក់លាក់នោះទេ វាអាស្រ័យទៅតាមស្ថាប័ន ឬគ្លីនិចឯកជនបានកំណត់ ប៉ុន្តែសំរាប់អ្នកដែលមានមេរោគអេដស៍/ ជំងឺអេដស៍ នឹងត្រូវទទួលបាននូវសេវាថែទាំបឋមដោយមិនមានបង់ថ្លៃនៅតាមគ្រឹះស្ថានសុខភាពសាធារណៈ និង ត្រូវបានលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជនផងដែរ ដោយយោងទៅតាមច្បាប់ស្តីពីការបង្ការ និងការ ប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ។ ទោះបីជាយ៉ាងនេះក៏ដោយ ស្ថាបន័ដែលពាក់ពន្ធ័ ជាពិសេសមកពីក្រុមហ៊ុនជ្រើសរើសពលករបានបញ្ជាក់ថា តំលៃនៃការធ្វើតេស្តលើមេរោគអេដស៍/ជំងឺអេដស៍ មេរោគថ្លើម និង ប្រភេទជំងឺមួយចំនួនទៀតដែលធ្វើឡើងដោយនាយកដ្ឋានពេទ្យការងារ និង ជាតំរូវការរបស់ ប្រទេសទទួល មានតំលៃខ្ពស់បើប្រៀបនឹងគ្លីនិចឯកជន និង ស្ថាប័នដទៃទៀតដែលក្រុមហ៊ុនមានទំនាក់ទំនង ជាមួយនៅភ្នំពេញក្នុងការធ្វើតេស្តពលករមុននឹងបញ្ជូនទៅធ្វើការនៅក្រៅប្រទេស ។

ដោយឡែក ក្រុមហ៊ុនជ្រើសរើសពលករមួយចំនួនបានបង្វែរទិសដៅនៃការពិនិត្យសុខភាពពលករ និង ការធ្វើតេស្តរករោមអេដស៍/ជំងឺអេដស៍ និង រោគថ្លើមជាមួយមន្ទីរពេទ្យរដ្ឋមួយចំនួនដែលមានទំនុចចិត្ត ពីប្រទេសទទួលជាជំនួសដោយការធ្វើតេស្តនៅនាយកដ្ឋានពេទ្យការងារដោយសារហេតុផលតំលៃ ។ថ្លៃគឺពី៤៥ទៅ ៥០ដុល្លាសហរដ្ឋអាមេរិច សំរាប់ការពិនិត្យសុខភាពនៅនាយកដ្ឋានពេទ្យការងារ ដោយរួមមានការធ្វើតេស្ត មេរោគអេដស៍/ជំងឺអេដស៍ រោគថ្លើម និង ប្រភេទជំងឺមួយចំនួនទៀតដែលបានកំណត់ដោយរាជរដ្ឋាភិបាល

ក្នុងបង់ថ្លៃដោយក្រុមហ៊ុន ជ្រើសរើសពលករ។ ម៉្យាងវិញទៀត មន្ទីរពេទ្យមួយចំនួនដែលមានទំនាក់ទងជាមួយ នឹងក្រុនហ៊ុន តំរូវអោយបង់ថ្លៃ ពី ២០ ទៅ ៣០ ដុល្លាសហរដ្ឋអាមេរិច សំរាប់ការធ្វើពិនិត្យសុខភាព និង ប្រភេទជំងឺមួយចំនួនទៀត នេះបើយោងតាមការបញ្ជាក់របស់នាយកក្រុមហ៊ុនជ្រើសរើសពលករមួយរូបនៅទីក្រុង ភ្នំពេញ។

*សំខាន់ខាងម៉ាឡេគេព្រមព្រៀងយកពេទ្យណាយើងចាំ គេឯកភាពសិន រួចយើងផ្ញើឈ្មោះពេទ្យ នៅស្រុកយើងអោយគេ ហើយគេស្រាវជ្រាវដោយខ្លួនគេ ឧបមាថាពេទ្យដែលគេបោះឆ្នោត គឺពេទ្យការងារ ក្រោយមកខាង delegation មិនអោយ មានបញ្ហាអីខ្ញុំអត់យល់ ក្រោយមកពេទ្យរូស្សីមានឡូហ្គូ Ministry of Health of Cambodia គេយករហូត ក្រុមហ៊ុន ខ្លះយកពេទ្យផ្សេងៗទៀត ក្រុមហ៊ុនគេយក ពេទ្យខុសៗគ្នា។ ខាងម៉ាឡេ គេគិតថាពេទ្យហ្នឹងមាន ក្របខ័ណ្ឌត្រឹមត្រូវគួរទុកចិត្ត ជាពិសេសគេឃើញ ឡូហ្គូក្រសួងសុខាភិបាលហើយខាងក្រសួងព្យាយាមទាក់ទងទៅម៉ាឡេអោយទទួល យកពេទ្យក្បាលថ្នល់ តែមកដល់ឥឡូវយើង មិនដឹងមានដំណើរការយ៉ាងម៉េចទេកាលលើកមុនៗគេយក ក្រោយមកគេអត់ យក ហើយក្រោយមក គេអត់យកវិញ ពេទ្យក្បាលថ្នល់ នេះទារមហាសែនថ្លៃ ហើយសព្វថ្ងៃនេះ ចំណាយអស់ ២០,២៥,៣០,៣៥ដុល្លាទេ តែពេទ្យក្បាលថ្នល់បង់ដល់ទៅ ៥០ដុល្លា រឺ៤៥ដុល្លារ (បុគ្គលិកក្រុមហ៊ុនជ្រើសរើសពលករ អេលីត ភ្នំពេញ)។*

ផ្អែកតាមការសំភាសន៏ជាមួយពលករដែលត្រៀមខ្លួនទៅធ្វើការនៅប្រទេសក្រៅបានឱ្យដឹងថាមាន លក្ខ-ខណ្ឌ័មួយចំនួនដែលជាឧបសគ្គក្នុងការទទួលសេវាតេស្តព្រោះថា ពួកគេត្រូវបានបញ្ជូនដោយភ្នាក់ងារកណ្តាលឬ ការិយាល័យសាខាដែលមានទីតាំងនៅតាមបណ្តារខេត្ត ឱ្យមកធ្វើតេស្តឈាមនៅការិយាល័យកណ្តាលក្រុងភ្នំពេញ ដែលជាកន្លែងដែលត្រូវបានពិនិត្យសុខភាព និងធ្វើតេស្តឈាមពលករ។ ក្នុងលក្ខខណ្ឌ័ខ្លះពលករត្រូវបានបូមឈាម នៅពេលដែលពួកគេបានមកដល់ទីស្នាក់ការក្រុមហ៊ុនជ្រើសរើសពលករ បើទោះជានៅតាមបណ្តារការិយាល័យ សាខាតាមខេត្តក្តី។ ដំណើរការនៃនីតិវិធីការធ្វើតេស្តនេះ ភាគច្រើនធ្វើឡើងដោយវេជ្ជបណ្ឌិតឬគ្រូពេទ្យដែលត្រូវ បានជួលដោយក្រុមហ៊ុន។

ក្នុងនោះដែរឈាមរបស់ពួកគេដែលបានបូមនៅការិយាល័យសាខាតាមខេត្តត្រូវបានបញ្ជូនមកភ្នំពេញដែលលទ្ធផល ត្រូវបានគេប្រាប់តាមរយៈទូរស័ព្ទទៅការិយាល័យសាខានៅតាមខេត្ត។ ម៉្យាងវិញទៀតតំលៃនៃការពិនិត្យសុខភាព ក៏ដូចជាការធ្វើតេស្តផ្សេង ត្រូវបានចំណាយដោយក្រុមហ៊ុនដែលពលករមិនបានដឹងពីការចំណាយទាំងនោះចំនួន ប៉ុន្មានសំរាប់ការធ្វើតេស្តនេះទេ។ ដោយឡែក រាល់ការចំណាយទាក់ទងនឹងការពិនិត្យសុខភាព ក៏ដូចជាការ ធ្វើតេស្តផ្សេងទៀតត្រូវបានទទួលខុសត្រូវដោយក្រុមហ៊ុន ដែលនឹងត្រូវកាត់ប្រាក់បៀវត្សរបស់ពួកគេជំនួសវិញ

ដោយផ្អែកតាមកិច្ចព្រមព្រៀងរវាងពលករ និងក្រុមហ៊ុនមុនពេលទៅធ្វើការក្រៅប្រទេស ដែលដំណើរការទាំងនេះភាគច្រើនត្រូវបានគេអនុវត្តន៍ចំពោះពលករដែលត្រៀមទៅធ្វើការនៅក្រៅប្រទេស។

*- ជួសឈាមនៅពាក់កណ្តាលផ្លូវ ខ្ញុំខ្លាចបូមមិនបាន ព្រោះខ្ញុំពិបាកចាក់ថ្នាំ*

*-ខ្ញុំជិះឡានមកមានអារម្មណ៍ភ័យខ្លាចធ្វើតេស្តឈាមអត់ជាប់ ហើយដល់កន្លែង បេនឡាន ទៅដល់លោកគ្រូគាត់ទទួលហើយនាំទៅពេទ្យឯកជនជួស់ឈាមពេលចុះពីលើឡានភ្លាមទៅជួសឈាមភ្លាមខ្ញុំមានអារម្មណ៏ភ័យឈឺបៗតែម្តងខ្ញុំមានអារម្មណ៏ថា ខ្ញុំប្រហែលជាមិនជាប់ទេច្បាស់ជាធ្លាក់ហើយលោកគ្រូគាត់នៅជិតខ្ញុំគាត់ដឹង គាត់ក៏និយាយ ថាឯងមិនធ្លាក់ទេមុខជាជាប់ហើយ ដល់ម៉ោង១១យប់គាត់តេមកប្រាប់ថាមាន២នាក់ ជាប់ចំណែកម្នាក់ទៀតធ្លាក់ ២នាក់ណាជាប់ខ្ញុំមិនដឹងដែរ។ ដល់ព្រឹកឡើងគាត់ប្រាប់អាមួយនេះ និងខ្ញុំ ជាប់ចំណែកម្នាក់ទៀតធ្លាក់។ ខ្ញុំខំតែភ័យ។ លោកគ្រូថាឯងកុំភ័យព្រោះអីតេស្តឈាមឯងថ្ងៃមុនជាប់ម្តង ហើយថ្ងៃនេះក៏ជាប់ដែរ (ពលការិនីត្រៀវទៅធ្វើការនៅម៉ាឡេស៊ុ ខេត្តបាត់ដំបង)។*

### ♦ ៣.២.១ ការត្រួតពិនិត្យគោលនយោបាយ និង នីតិវិធីនៃការធ្វើតេស្ត

គោលនយោបាយ យុទ្ធសាស្រ្ត ក៏ដូចជាគោលការណ៏ជាតិដែលកំពុងមានសំរាប់ការផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមបានចែងថា រាល់សារធាតុរាវដែលជាឈាមគួរតែត្រូវបានគេតេស្តជាបឋមដោយប្រើតេស្តធម្មតា ឬតេស្តឆាប់រហ័ស (Rapid Test) ប៉ុន្តែប្រសិនបើលទ្ធផលវិជ្ជមាន នោះការធ្វើតេស្តសារធាតុរាវ ដែលជាឈាមគួរតែត្រូវបានគេតេស្តសារជាថ្មីដោយប្រើតេស្តឆាប់រហ័សជាមួយ ELISA (Enzyme-Linked Immunosorbant Assay-an older type of “rapid” test where an antibody or antigen is linked to an enzyme as means of detecting a match between the antibody and antigen, and sometimes referred to as EIA) (ប្រភព: Voluntary Confidential counseling and Testing in Cambodia: An Overview by Gillian Fletcher, Policy and CARE, September 2003) លើសពីនេះទៅទៀត ការត្រួតពិនិត្យ និង គ្រប់គ្រងសេវាផ្តល់ប្រឹក្សា ធ្វើតេស្តដោយស្ម័គ្រចិត្ត និង រក្សាការសម្ងាត់ (Voluntary Confidential Counseling and HIV/AIDS Testing Centre: VCCT )នៅតាមការិយាល័យប្រតិបត្តិស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្រ្តីអេដស៏ខេត្តដែលខាងក្រោមជាការបទពណ៌នាពីការទទួលខុសត្រូវរបស់មន្ត្រីទាំងនោះ:

- តួនាទីមុខតំណែង : មន្ត្រីត្រួតពិនិត្យ និង គ្រប់គ្រងសេវាផ្តល់ប្រឹក្សា ធ្វើតេស្តដោយស្ម័គ្រចិត្ត និង រក្សាការងារសម្ងាត់ (ការិយាល័យប្រតិបត្តិថ្នាក់ខេត្ត)
- ទំនួលខុសត្រូវ : ទទួលខុសត្រូវចំពោះអ្នកគ្រប់គ្រងគំរោងអេដស៏ថ្នាក់ខេត្ត

ដោយឡែក ដើម្បីគ្រប់គ្រងនិងសម្របសម្រួលកម្មវិធីសេវាផ្តល់ប្រឹក្សា ធ្វើតេស្តដោយស្ម័គ្រចិត្ត និង រក្សាការសម្ងាត់ និងជំងឺកាមរោគនៅថ្នាក់ខេត្ត និងធានាថាវាបានបំពេញទៅដល់ក្រុមគោលដៅដែលជាយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិត្រូវបានគេរៀបចំសំរាប់សកម្មភាពអនាគតមានដូចជាៈ

- ការទទួលខុសត្រូវៈ
  - បណ្តុះបណ្តាលបុគ្គលិកសុខាភិបាល និង គ្រប់គ្រងសេវា VCCT នៅការិយាល័យប្រតិបត្តិ (OD)
  - សម្របសម្រួលរាល់ការបញ្ជូនដោយបណ្តាញផ្សេងៗ និងកំណត់មុខងារ
  - កំណត់ពីតំរូវការឱសថ និងការប្រើប្រាស់ដើម្បីផ្គត់ផ្គង់ទៅដល់ VCCT នៅតាមថ្នាក់ស្រុក និងធានាថាត្រូវបានគេប្រើប្រាស់ និង ចែកចាយ
  - ថែរក្សាកំណត់ត្រា VCCT និង ទិន្នន័យ
  - រៀបចំរបាយការណ៍ VCCT សំរាប់ថ្នាក់ខេត្ត
- ការទទួលខុសត្រូវរួមៈ
  - ខិតខំធ្វើការដោយបំពេញទៅតួនាទី និង ភារកិច្ច
  - ធ្វើការសហការទាំងក្នុង និង រវាងអង្គភាពថ្នាក់ខេត្ត និងស្រុកដើម្បីពង្រឹងការអនុវត្តន៍ថ្នាក់ខេត្តទាំងមូល
  - ធានាមានការចូលរួមជាទៀងទាត់ និងពេញលេញនូវរាល់ពេលវេលានៃម៉ោងធ្វើការ
  - ចំណាយពេលវេលាដើម្បីជួយការិយាល័យអេដស៏ថ្នាក់ខេត្ត ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់នៅរាល់សកម្មភាពផ្សេងៗ
  - ផ្តោតការយកចិត្តទុកដាក់ ចំពោះអ្នកគ្រប់គ្រងការិយាល័យអេដស៏ខេត្តចំពោះភាពមិនប្រក្រតីណាមួយ
  - ទទួលខុសត្រូវការងារផ្សេងទៀត ដែលប្រគល់ដោយអ្នកគ្រប់គ្រងនិងប្រធានកម្មវិធីអេដស៏ខេត្ត ។

- **៣.២ នៅប្រទេសទទួល**

បញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេសមានដូចជាប្រទេសថៃ ម៉ាឡេស៊ី និង សាធារណៈកូរ៉េ ជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រដទៃទៀតរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។បរិបទនៃការបញ្ជូននេះធ្វើឡើងតាមរយៈកិច្ចព្រមព្រៀង ឬអនុស្សារណៈយោគយល់គ្នារវាងរាជរដ្ឋាភិបាល និង រាជដ្ឋាភិបាលដែលបានអនុញ្ញាត្តិឱ្យក្រុមហ៊ុនឯកជនដំណើរការនៅក្នុងការបញ្ជូននេះ និង មានក្រសួងការងារនិង បណ្តុះបណ្តាល

វិជ្ជាជីវៈជាអ្នកគ្រប់គ្រងវិស័យនេះ។ បច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជា និងសាធារណៈរដ្ឋកូរ៉េ បានចុះអនុស្សារណៈយោគយល់គ្នា ក្នុងការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសកូរ៉េតាមប្រពន្ធ័អនុញ្ញាត្តិការងារ ដែលវាជានីតិវិធីមួយបានអនុញ្ញាត្តិអោយរដ្ឋាភិបាលធ្វើការផ្សព្វផ្សាយ និង ជ្រើសរើសពលករដោយមិនមានការចូលរួមពីភាគីឯកជនដូចជាការបញ្ជូនទៅធ្វើការនៅប្រទេសថៃ និង ម៉ាឡេស៊ី។
ក្នុងបែបផែននេះដែរ មុនពេលបញ្ជូនពលករទៅធ្វើការក្រៅប្រទេសគឺតំរូវអោយមានការពិនិត្យសុខភាព និង ធ្វើតេស្តមួយចំនួនទៀតដែលមាននៅក្នុងកិច្ចព្រមព្រៀងរវាងប្រទេសបញ្ជូន និងប្រទេសទទួល។

### ♦ ៣.២.១ នីតិវីធីនៃការធ្វើតេស្ត

ភាគច្រើនប្រទេសទទួលបានតំរូវអោយធ្វើការពិនិត្យសុខភាព មុនពេលដែលអនុញ្ញាត្តិឱ្យចូលប្រទេសគេ ដូចជាច្បាប់ប្រទេសម៉ាឡេស៊ីតំរូវអោយពលករធ្វើការពិនិត្យសុខភាពទៅរោគអេដស៍/ជំងឺអេសដ៏ ថ្លើម របេង និង កាមរោគ បន្ទាប់ពីបានទៅដល់។ ពេលវេលាកំណត់នៃការធ្វើតេស្តត្រូវបានកំណត់នៅពេលធ្វើការស្នើសុំបណ្ណ័អនុញ្ញាត្តិការងារជាថ្មីដោយមិនមានការផ្តល់ប្រឹក្សាមុន និង ក្រោយការធ្វើតេស្តនោះទេ ហើយពលករតំរូវអោយចុះហត្ថលេខាលើទំរង់នៃការយល់ព្រមជាមុនក្នុងការអនុញ្ញាត្តិអោយពិនិត្យសុខភាពសំរាប់បណ្ណ័អនុញ្ញាត្តិការងារជាថ្មី។ ទំរង់បានតំរូវថា ពលករបានចុះហត្ថលេខាយល់ព្រមក្នុងការបោះបង់ចោលនូវសិទ្ធជា ឯកជន មានភាពសម្ងាត់ និង អាចជាសិទ្ធិ មានការងារ និងសេរីភាពដោយរួមមានទំាងការរើសអើងនៅពេលលទ្ធផលតេស្តមេរោគអេដស៏/ជំងឺអេដស៏វិជ្ជមាន។ ក្នុងនោះដែរមានទិដ្ឋភាពជាច្រើននៃនីតិវិធីនេះត្រូវបានគេចោទសួរឡើង។ តើវាជាជំរើសដែលត្រូវផ្តល់អោយឬ? ថាតើផលវិបាកនៃការផ្តល់ការយល់ព្រមជាមុនសំរាប់ការធ្វើ តេស្តដោយបង្ខំ និងការនិរទេសយ៉ាងឆាប់រហ័ស ត្រូវបានគេយល់ និងដឹង និង ជាជំរើសមួយឬ។ នៅពេលដែលប្រឈមមុខនឹងតំរូវការនៃកាធ្វើតេស្ត និងជាផលវិបាក ដែលពលករប្រឈមមុខ នឹងការបាត់បង់ការពិចារណាផងនោះ ការធ្វើតេស្តឈាមដោយបង្ខំរកមេរោគអេដស៏/ជំងឺអេដស៏/ រោគថ្លើម សំរាប់ពលករដែលនៅប្រទេសម៉ាឡេស៊ី អារ៉ាប់ប៊ីសាអូឌីត សឹង្ហបូរី និង សាធារណៈរដ្ឋកូរ៉េ ជាការកាតូកិច្ចដែលត្រូវធ្វើជារៀងរាល់ឆ្នាំ នៅពេលដែលពលករធ្វើបណ្ណ័អនុញ្ញាត្តិការងារសារជាថ្មី ( ប្រភព: The Forgotten Space, Post Arrival, CARAM Aisa, 2002 ) ។

### ♦ ៣.២.២ ការត្រួតពិនិត្យពីគោលនយោបាយ និងនីតិវិធីនៃការធ្វើតេស្ត

ភាគច្រើននៃគោលនយោបាយថ្នាក់ជាតិមិនបានរួមបញ្ចូលនូវបញ្ហារបស់ពលករទៅក្នុងផែនការសកម្មភាពដើម្បីប្រយុទ្ធនឹងមេរោគអេដស៏/ជំងឺអេដស៏ ប៉ុន្តែប្រសិនបើបានរួមបញ្ចូល ជាធម្មតាបង្កើតនូវការធ្វើតេស្តចំពោះពលករមុននឹងចាកចេញ និង មុននឹងបានទទួលការងារ។ ដែលការអនុវត្តន៏នេះ វាបានរំលោភទៅលើ

សិទ្ធិមនុស្ស ជាមូលដ្ឋាន និងការបង្កើតនូវចំណាប់អារម្មណ៍ដែលថា ប្រទេសមួយត្រូវការពារនូវពលរដ្ឋរបស់ខ្លួនពីការចំណាកស្រុកដោយមិនផ្អែកទៅលើតំរូវការរបស់ពលករ។ នៅប្រទេសម៉ាឡេស៊ី គ្លីនិចឯកជនបានចុះបញ្ជីនៅក្រោមផ្នែកឯកជន FOMEMA (Foreign Worker Medical Examination Monitory Agency) ដែលទទួលខុសត្រូវក្នុងការពិនិត្យពលករមុនពេលអនុញ្ញាត្តិបណ្ណ័ការងារជាថ្មី ដែលភ្នាក់ងារនេះមានទំនាក់ទំនងដោយផ្ទាល់ជាមួយក្រសួងសុខាភិបាល និង ផ្នែកអន្តោប្រវេសន៏។ ប្រសិនបើ ពលករតេស្តមានលទ្ធផលវិជ្ជមាន និងមានជំងឺដទៃផ្សេងទៀតក្នុងចំណោមជំងឺដែលមាននៅក្នុងបញ្ជីរបស់រដ្ឋាភិបាលរួមមាន មេរោគអេដស៏/ជំងឺអេដស៏ ពួកគេនឹងត្រូវបាននិរទេសភ្លាម១ (ប្រភព: The Forgotten Space, Post Arrival, CARAM Aisa, 2002 )។

- **៣.៣ សមាហរណកម្ម**

មិនមានគោលការណ៏ ក៏ដូចជាច្បាប់ដែលតំរូវអោយមានការធ្វើតេស្តទៅលើពលករដែលត្រឡប់មកប្រទេសក្រៅនោះទេ ប៉ុន្តែក្នុងករណីជនរងគ្រោះដោយការជួញដូរត្រូវបានបញ្ជូនមកពីប្រទេសក្រៅនឹងត្រូវបានគេពិនិត្យសុខភាពដើម្បីធានាឱ្យប្រាកដថា សុខភាពរបស់ជនរងគ្រោះស្ថិតនៅក្នុងស្ថានភាពប្រក្រតី មុនពេលធ្វើសមាហរណកម្មទៅក្នុងសង្គមនិងគ្រួសារ (យោងបទបង្ហាញដោយវេជ្ជបណ្ឌិត ឱុមេ នៅអង្គការខារ៉ាមកម្ពុជា ១៩៩៨)។ ទោះបីជាយ៉ាងណាក៏ដោយ ពលករដែលមានបំណងដាក់ពាក្យសុំជាថ្មីទៅធ្វើការនៅក្រៅប្រទេសនឹងតំរូវអោយធ្វើការពិនិត្យសុខភាព បើទោះបីបានបញ្ចប់កិច្ចសន្យាក្តី។

មានពលករដែលត្រលប់មកវិញជាច្រើនបានធ្វើតេស្តមានលទ្ធផលវិជ្ជមាន ប្រឈមនឹងការបដិសេធ ស្តីបន្ទោស និង ការរើសអើងពីក្រុមគ្រួសារ ក៏ដូចជាភ្នាក់ងារឯកជនផងដែរ។ ចំពោះការវិលត្រលប់មកវិញរបស់ពលករនេះគឺពួកគេមានកង្វះខាតនូវការថែទាំ គាំទ្រ និង ព្យាបាល ក៏ព្រោះតែ ការអវត្តមាននៃការផ្តល់ប្រឹក្សាក្រោយការធ្វើតេស្ត ដែលបានបង្កើតនូវភាពតានតឹងក្នុងអារម្មណ៏របស់ពួកគេ។ ពលករដែលត្រលប់មកពីប្រទេសក្រៅវិញគឺពួកគេមកពីគ្រួសារក្រីក្រ និងប្រទេសក្រីក្រ ដែលពួកគេមិនមានលទ្ធភាពទៅរកសេវាសំរាប់ការព្យាបាលបាន។ ទាំងនេះជាការបន្ថែមនូវពិការភាព និងភាពគ្មានអំណាចដល់ពួកគេបន្ថែមទៀត (ប្រភព: The Forgotten Spaces, Abridged Version, CARAM ASIA 2004)។

## ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

**អារម្មណ៏របស់ពលករ**

ដោយមានច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ប៉ុន្តែ មិនទាន់ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណៈមតិនោះទេ ក្នុងន័យនេះពលករយល់ថាល្អដែលត្រូវបានគេពិនិត្យសុខភាព ក៏ដូចជាពិនិត្យឈាមដែលតំរូវដោយក្រុមហ៊ុនជ្រើសរើសពលករមុនពេលទៅធ្វើការក្រៅប្រទេស បើទោះបីជាបញ្ហានេះផ្ទុយទៅនឹងច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែជាលក្ខខណ្ឌតំរូវរបស់ប្រទេសទទួល ក្នុងការទទួលយកពលករបរទេសទៅធ្វើការនៅប្រទេសរបស់គេ។ ម្យ៉ាងវិញទៀត ពលករមានទស្សនៈថា វាមានសារៈសំខាន់ និងប្រយោជន៍ខ្លាំងណាស់សំរាប់ពួកគេដែលត្រូវបានពិនិត្យសុខភាពនិងធ្វើតេស្តឈាមព្រោះថា ពួកគេអាចដឹងពីស្ថានភាពសុខភាពរបស់គេដោយមិនចាំបាច់ចំណាយថវិការសំរាប់ថ្លៃសេវាបើទោះជាលទ្ធផលធ្លាក់ ឬជាប់ ក៏ដោយ។ ដោយឡែក ពួកគេនឹងរីករាយប្រសិនបើលទ្ធផលនៃការធ្វើតេស្តអវិជ្ជមាន ដែលពួកគេនឹងត្រូវបានគេអនុញ្ញាតិ ឱ្យទៅធ្វើការនៅក្រៅប្រទេសដូចដែលគេរំពឹងទុក ប៉ុន្តែប្រសិនបើលទ្ធផលមានលក្ខណៈវិជ្ជមាន នោះពួកគេមិនមានជំរើសក្រៅតែពីត្រូវបានគេធ្វើមាតុភូមិនិវត្តន៍ទៅសហគមន៍របស់ពួកគេវិញដោយមិនបានទទួល នូវការផ្តល់ប្រឹក្សាពីអ្នកជំនាញ នឹងអាចជំរុញឱ្យគេមានភាពអស់សង្ឃឹមចំពោះលទ្ធផល និងគោលបំណងដោយចង់ទៅធ្វើការនៅក្រៅប្រទេស ដើម្បីបានថវិការមកជួយផ្គត់ផ្គង់នៅក្នុងគ្រួសារ។ ក្នុងនោះដែរ ពួកគេអាចនឹងត្រូវបានរើសអើងដោយសហគមន៍ និង អ្នកជិតខាងផងដែរ។

**អានុសាសន៍**

- មិនមានគោលនយោបាយ ក៏ដូចជាច្បាប់ដែលតំរូវអោយវេជ្ជបណ្ឌិតប្រុសត្រូវពិនិត្យអតិថិជនបុរស និង វេជ្ជបណ្ឌិតស្រីពិនិត្យអតិថិជនស្ត្រីដើម្បីធានាពីក្រមសីលធមិរបស់វេជ្ជបណ្ឌិតនោះទេ ដែលបញ្ហានេះគួរតែត្រូវបានគេអនុវត្តន៏ចំពោះពលករចំណាកស្រុក ដែលនឹងទៅធ្វើការនៅក្រៅប្រទេស និងត្រូវបានគេពិនិត្យសុខភាព និងតេស្តឈាមនៅតាមបណ្តារមន្ទីរពេទ្យរដ្ឋនានា ជាពិសេស នាយកដ្ឋានពេទ្យការងារ ដែលមានកង្វះខាតវេជ្ជបណ្ឌិត ឬគ្រូពេទ្យស្រីក្នុងការបំពេញភារកិច្ចនេះ និងភាគច្រើនពលករត្រូវបញ្ជូនទៅធ្វើតេស្តឈាមដោយក្រុមហ៊ុនជ្រើសរើសពលករ។ លើសពីនេះ ភាគច្រើនពលករដែលបញ្ជូនទៅធ្វើការនៅក្រៅប្រទេស ច្រើនតែជាស្ត្រីដែលត្រូវបំពេញការងារជាអ្នកជំនួយការក្នុងផ្ទះ នៅតាមចំការ ភោជនីយដ្ឋាន និងឧស្សាហកម្មផ្សេងៗទៀត។ អាស្រ័យហេតុនេះពួកគេ អាចនឹងមានការអៀនខ្មាស់ក្នុងការចែករំលែកនូវ

ពតិមាន ក៏ដូចជាសាកសួរដល់វេជ្ជបណ្ឌិត/គ្រូពេទ្យនូវចម្ងល់របស់ពួកគេកំឡុងពេលពិនិត្យសុខភាព ការធ្វើតេស្តឈាម ដែលទាំងនេះជាវប្បធម៌ និងប្រពៃណីទំនៀមទំលាប់។

- ដោយឡែក ក្រុមហ៊ុនជ្រើសរើសពលករគួរតែជួលវេជ្ជបណ្ឌិត ឬគ្រូពេទ្យដែលជំនាញដើម្បីធ្វើតេស្តឈាមពលករដែលដាក់ពាក្យសុំទៅធ្វើការនៅក្រៅប្រទេស និងដើម្បីធានាថា ការពិនិត្យសុខភាព និង ធ្វើតេស្តឈាម ត្រូវបានអនុវត្តទៅតាមបទដ្ឋានដែលមានចែងនៅក្នុងច្បាប់ និងកំណត់ដោយក្រសួងសុខាភិបាល។ ម៉្យាងវិញទៀត លទ្ធផលនៃការធ្វើតេស្តរកមេរោគអេដស៍/ជំងឺអេដស៍គួរត្រូវបានគេបង្ហាញដល់ពលករដោយមានការផ្តល់ប្រឹក្សាមុននិងក្រោយការធ្វើតេស្ត ដោយអ្នកជំនាញខាងផ្តល់ប្រឹក្សាក្នុងលក្ខខណ្ឌមួយទល់មួយដោយធ្វើយ៉ាងណាអោយពលករអាចទទួលយកនូវលទ្ធរបស់គេដោយមិនមានការបាក់ទឹកចិត្ត។

- ក្នុងនោះដែរ ក្រុមហ៊ុនជ្រើសរើសពលករគួរតែមានប្រព័ន្ធបញ្ជូនសំរាប់ពលករដែលលទ្ធផលធ្វើតេស្តវិជ្ជមានទៅរកសេវសុខភាពសមស្របណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាពីផលប៉ះពាល់នៃលទ្ធផលដែលមិនត្រូវបានរើសអើងពីសំណាក់មិត្តភក្រ្តអ្នកជិតខាងក៏ដូចជាក្រុមគ្រួសារ និងសង្គម។

- តាមរយៈការប្រតិបត្តិ វេជ្ជបណ្ឌិត ឬគ្រូពេទ្យដែលកំពុងធ្វើការនៅតាមមណ្ឌលសុខភាព ក៏ដូចជាគ្លីនិចឯកជនក្នុងការធ្វើតេស្តឈាមរកមេរោគអេដស៍/ជំងឺអេដស៍ ជាមួយពលករគួរតែត្រូវបានផ្តល់ការបណ្តុះបណ្តាលពីជំនាញអ្នកផ្តល់ប្រឹក្សា និងច្បាប់ស្តី ពីការបង្ការនិងការ ប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ដើម្បីធ្វើអោយធានាថាពលកររីករាយនឹងលទ្ធផលការធ្វើតេស្ត។

- ម៉្យាងវិញទៀត ច្បាប់ស្តីពីការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ គួរតែត្រូវបានគេផ្សព្វផ្សាយជាសាធារណៈបន្ថែមទៀតទៅដល់វេជ្ជបណ្ឌិត ឬគ្រូពេទ្យបុគ្គលិកសុខាភិបាល អ្នកផ្តល់ប្រឹក្សា និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីអោយបានជ្រួតជ្រាបក្នុងការគោរពតួនាទី ភារកិច្ច និងក្រមសីលធម៌ក្នុងគោលបំណងបំរើសុខភាពប្រជាពលរដ្ឋ។

- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសនាយកដ្ឋានពេទ្យការងារគួរមានអ្នកជំនាញផ្តល់ប្រឹក្សាក្នុងការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ ជាមួយពលករដែលត្រៀមខ្លួនទៅធ្វើការ

នៅក្រៅប្រទេស ដោយអនុវត្តន៍អោយបានជាក់លាក់នូវភារកិច្ច ក៏ដូចជាពង្រឹងច្បាប់ ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ក្នុងគោលបំណងការពារសិទ្ធិមនុស្សរបស់ពួកគេ។ អាស្រ័យហេតុនេះ រាល់ពលករដែលត្រៀមទៅធ្វើការនៅក្រៅប្រទេសទាំងអស់ ត្រូវបានផ្តល់ការប្រឹក្សាមុន និងក្រោយការធ្វើតេស្តរកមេរោគអេសដ៍/ជំងឺអេដស៍ និងរក្សាការសម្ងាត់។

- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរតែរឹតបន្តឹងចំពោះក្រុមហ៊ុនជ្រើសរើសពលករដែលជួលវេជ្ជបណ្ឌិត ឬ គ្រូពេទ្យក្រៅបន្ថែមក្នុងការបូមយកឈាមរបស់ពលករ ដែលកំពុងដាក់ពាក្យទៅធ្វើការនៅក្រៅប្រទេសមុនពេលបញ្ជូនពួកគេទៅពិនិត្យសុខភាព ក៏ដូចជាការធ្វើតេស្តឈាមនៅនាយកដ្ឋាន ពេទ្យការងារ ដែលកត្តានេះជាបញ្ហាគ្រោះថ្នាក់ មួយនាំអោយពលកររស់នៅក្នុងស្ថានភាពគ្រោះថ្នាក់ដោយមិនបានទទួលសេវាគាំទ្រ និងការគាំទ្រពីក្រុមគ្រួសារ មិត្តភក្ត្រ អ្នកជិតខាង និងសង្គម ប្រសិនជាលទ្ធផលរបស់ពួកគេវិជ្ជមាន ព្រមទាំងធ្វើយ៉ាងណាឱ្យសិទ្ធិរបស់ពួកគេត្រូវបានការពារនិងធានា។

## ៥. ឯកសារយោង


- Raksmeiy Kampuchea Daily News, Year $15^{th}$, Issued N° 4272, Tuesday, May, $01^{st}$, 2007
- Policy, Strategy and Guidelines for HIV/AIDS Counseling and Testing in Cambodia $2^{nd}$ Edition, September 2004, NCHADS
- Sub-degree 57 on Sending Khmer Workers to Work Abroad, 20 July 1995
- Cambodia Law on the Prevention and Control HIV/AIDS
- Guideline for Establishment Voluntary Confidential Counseling and HIV Testing (VCCT) Center, NCHADS 2004
- Voluntary Confidential Counseling and Testing in Cambodia: An Overview by Gillian Fletcher, Policy and CARE, September 2003
- The Forgotten Spaces, Post Arrival, CARAM Asia, 2002
- The Forgotten Spaces, Abridged Version, CARAM Asia, 2004